សារព័ត៌មាន ខ្មែរផុស ស.រ.អា
# KhmerPost USA

Free Copies
Email:Khmerpostusa@gmail.com
www.khmerpostusa.com

Vol. 15. Issue 361, Apr 10, 2024 | Direct: 978-656-8141
Lowell - Lynn - Revere - MA * Providence - Cranston - RI

# វិភាគការវិវត្តន៍នយោបាយសេដ្ឋកិច្ចពិភពលោក

តទៅទំព័រទី០៣



# បោះឆ្នោត«ស៊ូព័រធ្វូស្ដេយ»នរណាជាបេក្ខជនប្រធានាធិបតីអាមេរិកាំង?



ខ្មែរផុសអឺរ៉ុប ◉ ថ្ងៃទី០១មិនា២០២៤

*សូមអាននៅទំព័រ ០៧*






# «ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ»ទើបនឹងផុសចេញមកនៅសហរដ្ឋអាមេរិក

ពីអឺរ៉ុប * ថ្ងៃទី០១មេសា២០២៤

លោកស្រីអនុប្រធានគណបក្សសង្គ្រោះជាតិ មូរ សុខហួរ បានចេញសេចក្តីប្រកាសថ្មីមួយ តាមវិទ្យុអាមេរីកាំងមួយថា លោកស្រីទើបនឹងបានបង្កើត«ចលនាដើម្បីប្រជាធិបតេយ្យ»មួយដើម្បីទៅជួយសង្គ្រោះកម្ពុជាដែលកំពុងតែធ្លាក់ក្នុងរបបផ្តាច់ការ គ្រួសារនិយម ហើយឲ្យពិភពលោកអាចនឹងទទួលស្គាល់កម្ពុជាឡើងវិញបានដោយការបង្ហាត់បង្រៀននឹងអនុវត្តិលទ្ធិប្រជាធិបតេយ្យ។ លោកស្រីបានធ្វើសេចក្តីប្រកាសនេះ នៅពេលដែលលោកស្រីចេញពីការិយាល័យផ្តល់ជំនួយលើកដំកើងប្រជាធិបតេយ្យអាមេរីកាំងមួយនៅទីក្រុងវ៉ាស្ហីងតុនកាលពីដើមខែមិនានេះ។

លោកស្រី មូរ សុខហួ ធ្លាប់មានដំណែងជារដ្ឋមន្ត្រីក្រសួងកិច្ចការនារីខាងគណបក្សហ្វុនស៊ិនប៉ិច នាអម្លុងឆ្នាំ១៩៩៥ ក្រោយមកក៏ចូលរួមជាមួយគណបក្សសមរង្ស៊ីវិញ តស៊ូក្នុងគណបក្សប្រឆាំងនោះរហូតដល់គណបក្សសង្គ្រោះជាតិ បានត្រូវរំលាយដោយគណបក្សកាន់អំណាច នាឆ្នាំ២០១៧, លោកស្រីរស់នៅនិរទេសខ្លួនឯងសហរដ្ឋអាមេរីក ក្បែរទីក្រុងឡូវែលដើម្បីគេចពីការចោទប្រកាន់រកចាប់ខ្លួនរបស់តុលាការខ្មែរ រហូតដល់ពេលនេះ។

វត្ថុបំណងនៃសេចក្តីប្រកាសនោះ



លោកស្រី មូរ សុខហួ កំពុងដឹកនាំបាតុកម្មមួយ

គឺចង់ទៅជួយបង្ហាត់បង្រៀនលទ្ធិប្រជាធិបតេយ្យដល់មន្ត្រីនឹងប្រជាពលរដ្ឋខ្មែរ ពីទស្សនៈវិជ្ជា នឹងការអបរំនៃលទ្ធិប្រជាធិបតេយ្យ

តទៅទំព័រទី១៦

# Khmer Movement for Democracy has just emerged in the United States

**From Europe 1 April 2024**

CNRP Vice President Mu Sochua issued a new statement on American radio stating that she had just formed a "movement for democracy" to rescue Cambodia, which was falling into a family dictatorship, and for the world to recognize Cambodia by training and practicing democracy. She made the announcement as she left an American Democratic Aid office in Washington earlier this month.

Mu Sochua served as FUNCINPEC's Minister of Women's Affairs during 1995 and later joined the Sam Rainsy Party as the opposition until the CNRP was dissolved by the ruling party in 2017. She escaped to the United States near Lowell to escape Cambodian court arrest charges.

The purpose of the declaration is to help educate Cambodian officials and people about the philosophy and education of democracy in Cambodia, which she believes will enhance Cambodia's image, which has been damaged by the lack of democracy. The practice of democracy is there. She added that this was not to go against the government, but to help the new government.

No response has been received from the Cambodian government yet, but the announcement was echoed by the Khmer Will Party and Caddle Light Party in Phnom Penh, it was the first senior opposition official. It could be an attempt to open a new page to find a formula for national unity between the government and the opposition, which has been tense and violent for a long time.






# វិភាគការវិវត្តន៍នយោបាយសេដ្ឋកិច្ចពិភពលោក

*អឺរ៉ុប, ខែមេសា២០២៤*

*ដើមហេតុនៃការវិវត្តន៍សេដ្ឋកិច្ចសាកល*

នៅឆ្នាំ ២ ០ ២ ៤ នេះ អ្នកសង្កេតការសេដ្ឋកិច្ចបានពិនិត្យឃើញថា មានគម្លាតកំណើនសេដ្ឋកិច្ចរវាងប្រទេសលោកសេរី នឹងប្រទេសកុម្មុយនិស្តកាន់តែច្រើនឡើងក្នុងដំណើរផ្ទុយគ្នាពីអម្លុងឆ្នាំ១៩៩០នឹងឆ្នាំ២០២៤នេះ។ នាអម្លុងឆ្នាំ១៩៩០នោះប្រទេសអាមេរីកបានលើកទឹកចិត្តឲ្យប្រទេសចិនរុស្ស៊ីនឹងវៀតណាមកុម្មុយនីស្ត ចូលរួមក្នុង«ផ្សារសេរីពិភពលោក»ជាថ្នូរនឹងការគោរពសិទ្ធិមនុស្ស(ពីខាងប្រទេសកុម្មុយនីស្តនឹងបញ្ចប់សង្គ្រាមវៀតណាមខាងសហរដ្ឋអាមេរីក) ដោយប្រទេសកុម្មុយនីស្តទាំង៣នោះ ជាប្រទេសចូលចិត្តធ្វើសង្គ្រាម នឹងគាបសង្កត់ប្រជាពលរដ្ឋខ្លួនឯង ទាំងប្រទេសខ្លួនឯងក្រីក្រសោះ ។

ការសម្រេចចិត្តចូលរួម



ស៊ី ជីងពីង ប្រធានាធិបតីចិន នឹង ពូទីន ប្រធានាធិបតីរុស្ស៊ី ព្រមព្រៀងគ្នាបំផ្លាញប្រទេសលោកខាងលិច

រកស៊ីក្នុងសហាគមន៍ផ្សារសេរីរបស់ប្រទេសចិន រុស្ស៊ីនឹងវៀតណាមបានធ្វើឲ្យប្រទេសកុម្មុយនីស្តទាំង៣ បានប្តូរមុខមាត់យ៉ាងសម្បើម ដោយ

តទៅទំព័រទី០៦

# Analysis of global economic and political developments

***Europe, April 2024***

*The causes of global economic development*

In 2024, economic observers have observed that the economic growth gap between the liberal and communist countries is widening in the opposite direction from 1990 to 2024. During the 1990s, the United States encouraged communist China, Russia, and Vietnam to join the "World Free Market" in exchange for respect for human rights (from the communist side to the end of the Vietnam-US war) by the three communist countries. That is a country that loves war and oppresses its own people and its own poor country.

The decision to join the free market community of China, Russia and Vietnam has changed the face of the three communist countries, with rich countries such as the United States and Europe also investing in the communist countries as traders. Manufacturers of consumer goods, electronics, and foodstuffs ... made cheap, which makes the goods in the free market and goods of the free countries

**Please see /06**

**ឱកាសការងារមកដល់ហើយ សូមមកដាក់ពាក្យ បើកបរឡានក្រុង LRTA នៅឡូវែល**

Lowell Transit Authority កំពុងជួលអ្នកបើកបរឡានក្រុងពេញម៉ោង។ វាបង់ប្រាក់ខែល្អមានផ្តល់រហូតដល់ 401K ធានារ៉ាប់រងសុខភាព និងអាយុជីវិត។ CDL-A ឬ CDL-Bទាមទារតម្រូវឱ្យអ្នកដំណើរយល់ព្រម។ សូមផ្ញើប្រវត្តិរូបសង្ខេបមកកាន់អ្នកគ្រប់គ្រងទូទៅ តាមអ៊ីម៉ែល customerservice@LRTA.com ឬដាក់ពាក្យដោយផ្ទាល់នៅ៖ 100 Hale Street ។ ឡូវែល, MA ។ បើកថ្ងៃច័ន្ទ ដល់ សុក្រ ពីម៉ោង 8 ព្រឹក ដល់ 4 ល្ងាច។ ទូរស័ព្ទ៖ ៩៧៨-៤៥២-៦១៦១៕



សុខឿន មួន អ្នកបើកបររថយន្តក្រុង LRTA



# រុស្សីបោះឆ្នោតប្រធានាធិបតី អ៊ុយក្រែនស្ងប់ស្ងាត់

ក្នុងសប្តាហ៍ទី២នៃខែមីនានេះ នៅប្រទេសរុស្ស៊ីកំពុងបោះឆ្នោតប្រធានាធិបតីការវាយលុកទៅអ៊ុយក្រែនក៏បន្ថយល្បឿន ហើយក៏អនុញ្ញាត្តិឲ្យ ប្រធានាធិបតីវូឡូឌីមៀជេឡិនស្គីអាចចេញទៅធ្វើទស្សនកិច្ចទៅប្រទេសជាច្រើន ដើម្បីបង្កើនទំនាក់ទំនងចំណងមិត្តភាពផង នឹងស្វែងរកជំនួយសម្រាប់ធ្វើសង្គ្រាមតតាំងនឹងរុស្ស៊ីផង ស្របគ្នានឹងជំនួយសម្ភារៈសឹកពីអាមេរីក អ៊ុយក្រែនមិនបានទទួលទេនោះ។

បេក្ខជនប្រធានាធិបតី ពូទីន បានត្រូវគេមើលឃើញថា លោកមុខជានឹងជាប់ឆ្នោតសម្រាប់អាណត្តិទី៥ ជាបន្តទៀតជាមិនខាន ដោយសារបេក្ខជន ឬបេក្ខនារីដែលប្រឆាំងនឹងនយោបាយលោក នឹងត្រូវជាប់គុកឬក៏ស្លាប់ ដូចអ្នកប្រឆាំងដ៏ល្បីល្បាញ ណាវ៉ាល់នៀ បានត្រូវស្លាប់នៅក្នុងគុក មុនពេលបោះឆ្នោត



Russian Presidential candidates
Vladisla Davanko, Leonid Sloutsky, Valdimir Poutine , Nikolai Kharitono

យ៉ាងគួរឲ្យសង្ស័យ, បេក្ខជន២នាក់ទៀត ដែលប្រឆាំងនឹងសង្គ្រាមនៅអ៊ុយក្រែន បែរជាគ្មានសិទ្ធឈរឈ្មោះជាបេក្ខជន នៅសល់បេក្ខជននៃគណបក្សតូចតាច៣រូបទៀត ដែលយល់ស្របតាមនយោបាយសង្គ្រាមរបស់ ពូទីន ទើបអាចឈរឈ្មោះជាបេក្ខជនប្រជែងនឹង ពូទីន



អង្គការសហប្រជាជាតិនឹងសមាជិកទាំងអស់បានបោះឆ្នោតមិនគាំទ្រការបោះឆ្នោតនៅរុស្ស៊ីនោះទេ

បាន។

ជេឡិនស្គី ក្នុងដំណើរទស្សនកិច្ចរបស់លោកបានថ្លែងប្រាប់ទៅអ្នកកាសែតថា«ជាការបោះឆ្នោតនៅរុស្ស៊ី ជាការបោះឆ្នោតក្លែងក្លាយកុំឲ្យពិភពលោកទទួលស្គាល់ការបោះឆ្នោតនៅរុស្ស៊ីនោះ»។ នៅបារាំងលោក ជេឡិនស្គី បានទទួលការគាំទ្រស្វាគមន៍យ៉ាងកក់ក្ដៅពីលោកប្រធានាធិបតី ម៉ាក្រុង លោកបានធ្វើសេចក្ដីថ្លែងការ នៅចំពោះលោក ជេឡិនស្គី ថា«យើងមិនអាចឲ្យរុស្ស៊ីឈ្នះអ៊ុយក្រែន បានទេ!» ហើយក៏បន្ថែមទៀតថា«លោកអាចនឹងបញ្ជូនទ័ពជើងគោកទៅកាន់អ៊ុយក្រែនទៀតផង»តែសមាជិកនៅអូតង់ទាំងអស់ រាប់ទាំងអាល្លឺម៉ង់ អង់គ្លេស ឬ អាមេរីក មិនបានយល់ស្របទេ ដោយគេខ្លាច ពូទីន បង្ក«សង្គ្រាមណូក្លេអ៊ែ»តបវិញ នៅអឺរ៉ុប។ លោក សាលមីសែល ប្រធានសភាសហភាពអឺរ៉ុប បានថ្លែងចំពោះលោក ពូទីន ថា«ខ្ញុំសុំសសើចំពោះជ័យជំនះដ៏ត្រចះត្រចង់របស់លោក»ដែលពាក្យនោះ ក៏បានក្លាយជាការចំអកមួយដោយ សេចក្ដីសសើនោះ ធ្វើឡើងនៅមុនពេលចាប់ប្ដើមបោះឆ្នោត ហើយគឺមុនពេលទទួលបាន លទ្ធផលនៃជ័យជំនះរបស់ ពូទីន។

ពូទីន បានឈ្នះឆ្នោតដូចគ្រោងទុកមែន ដោយគ្មានការកោតសសើរពីប្រទេសសេរីណាមួយទេ ពីព្រោះជនផ្ដាច់ការនិយមត្រូវការតែអំណាចដើម្បីសម្រេចមហិច្ឆិតារបស់ខ្លួន ជាម្ចាស់នៃប្រទេសរុស្ស៊ី ហើយបន្តវាយផ្ដាច់ព្រ័តយកអ៊ុយក្រែន ជាពានរង្វាន់ សម្រាប់សម្លឹងទៅអំណាចពិភពលោក, មុននឹងបន្តនៅដើមអាណត្តិថ្មី គេទាយថា ពូទីន នឹងវាយប្រទេស«អូតង់ ឬសេអាតូ»ឯទៀតៗ ជាមិនខាន។ កងកម្លាំងអូតង់បានយល់ពីគម្រោងរបស់ពូទីនោះ ក៏ប្ដើមធ្វើសមយុទ្ធយ៉ាងប្រញាប់ប្រញាល់មួយ ជាមួយប្រទេសចូលអូតង់ថ្មីផ្មោង ដែលមានព្រំដែលជាប់នឹងរុស្ស៊ី ប្រទេសទាំងនោះ ឈប់នៅជាអព្យាក្រឹតក៏ចូលអូតង់ ពីព្រោះខ្លាចរុស្ស៊ីវាយប្រហារដូចអ៊ុយក្រែនទៀត។

ប្រទេសថ្មីនៃអង្គការអូតង់ មាន យូគ្គោស្លាវី ហ្វាំងឡង់ នឹង ស៊ុយអែដ ដែលទើបនឹងក្លាយជាសមាជីកនាខែមិនា២០២៤ នេះ ធ្វើឲ្យអូតង់មានសមាជិកដល់ទៅ៣២ប្រទេស។

ការបោះឆ្នោតនេះ គឺបោះទូទាំងប្រទេស ដែលមានទំហុំធំជាងគេបង្អស់លើពិភពលោក មានគម្លាតពីខាងកើតដល់ខាងលិចចំនួន១១ម៉ោង ពលរដ្ឋនៅរុស្ស៊ីទាំងអស់ត្រូវទៅបោះឆ្នោត រួមទាំងពលរដ្ឋនៅទឹកដីអ៊ុយក្រែន កាន់កាប់ដោយរុស្ស៊ី មានគ្រីម៉េ ដុងណេស ស្ទាប់ប៉ូរិស្ទាគែសុន ជាដើម ក៏ឲ្យចូលរួមបោះឆ្នោតដែរនោះហើយដែលអង្គការសហប្រជាជាតិនឹងសមាជិកបានប្រឆាំងនឹងការបោះឆ្នោតរុស្ស៊ី ដោយសារតែបោះឆ្នោតខុសច្បាប់អន្តរជាតិ នៅលើដែនដីត្រួតត្រានៅអ៊ុយក្រែននោះ។

នៅក្នុងដែនដីត្រួតត្រានោះ ពលរដ្ឋមិនសូវដឹងពីនយោបាយទេ មន្ត្រីបោះឆ្នោត គេយកហិបឆ្នោតទៅឲ្យបោះឆ្នោតដល់ផ្ទះ។ ពលរដ្ឋរុស្ស៊ីទូទៅមិនបានឃើញនរណាផ្សេងក្រៅពីលោក ពូទីន ជាប្រធានាធិបតីទេ ពីព្រោះគេចង់ឲ្យសង្គ្រាមឆាប់ចប់ ហើយកូនចៅបងប្អូនគេត្រឡប់មកផ្ទះវិញតែប៉ុណ្ណោះ៕






# លោក កឹម សុខា បន្តបដិសេធថាលោកមិនបានឃុបឃិតជា មួយរដ្ឋបរទេសដើម្បីផ្តួលរំលំរដ្ឋាភិបាលដូចការចោទប្រកាន់ទេ

ប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា នៅតែបន្តការពារភាពស្អាតស្អំរបស់ខ្លួនថាមិនបានឃុបឃិតជាមួយរដ្ឋបរទេសដូចការចោទប្រកាន់របស់សាលាដំបូងរាជធានីភ្នំពេញ ដែល



លោក កឹម សុខា

បានសម្រេចកាត់ទោសពីបទ «ក្បត់ជាតិ» នោះទេ ខណៈអង្គសវនាការនៅថ្ងៃទី៤ មេសា នេះបានជជែកដេញដោលលើអង្គហេតុចំនួន៣។

សហមេធាវីការពារក្តីលោក កឹម សុខា អ្នកស្រី ម៉េង សុភារី បានថ្លែងថា នៅក្នុងសវនាការលើកទី៦ នៅព្រឹកថ្ងៃទី ៤ ខែមេសា ឆ្នាំ២០២៤ នេះ នៅសាលាឧទ្ធរណ៍ លោក កឹម សុខា នៅតែបន្តការពារភាពស្អាតស្អំរបស់ខ្លួនលើការចោទប្រកាន់របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចកាត់ទោសលោកឱ្យជាប់ពន្ធនាគារចំនួន ២៧ឆ្នាំ ពីបទ «ក្បត់ជាតិ»។ អ្នកស្រីថា លោក កឹម សុខា បានអះអាងការពារភាពស្អាតស្អំរបស់គាត់ថា គាត់មិនបានឃុបឃិតជាមួយបរទេសដូចការចោទប្រកាន់នោះទេ។

ចំណែកមន្ត្រីសមាគមការពារសិទ្ធិមនុស្សអាដហុក លោកយី សុខសាន្ត ដែលបានចូលរួមតាមដានសវនាការ បានឲ្យដឹងថា អង្គសវនាការនៅថ្ងៃពុធទី៣ មេសា នេះបានជជែកដេញដោលលើអង្គហេតុចំនួន៣ គឺទី១ ថ្ងៃចន្ទពណ៌ខ្មៅ ទី២ ផ្កាឈូក និងទី៣ កណ្ដាប់ដៃ។ លោកថា លោ កឹម សុខា នៅតែបដិសេធថាលោកពុំបានឃុបឃិតជាមួយបរទេសនោះទេ។

កាលពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ សាលាដំបូងរាជធានីភ្នំពេញ បានផ្តន្ទាទោសប្រធានគណបក្សសង្គ្រោះ

តទៅទំព័រទី២៩

# Kem Sokha continues to deny that he did not conspire with foreign states to overthrow the government as alleged

CNRP president Kem Sokha continues to defend his innocence by refusing to conspire with foreign states, as alleged by the Phnom Penh Municipal Court, which has decided to try him for "treason" while the debate took place on 04 April on three facts.

Kem Sokha's co-lawyer, Ms. Meng Sopheary, stated that in the sixth hearing on the morning of April 4, 2024, at the Court of Appeal, Mr. Kem Sokha continued to defend his innocence on the charges of the Phnom Penh Mu-

Please see /29



តមកពីទំព័រទី ០៣

# វិភាគការវិត្តនយោបាយសេដ្ឋកិច្ច...

ប្រទេសអ្នកមានលុយច្រើន មានអាមេរិកនឹងអឺរ៉ុប គេក៏នាំគ្នាចូលទៅវិនិយោគនៅក្នុងប្រទេសកុម្មុយនីស្តជាពាណិជ្ជករជាឧស្សាហករជាផលិតករនូវគ្រឿងបរិក្ខារប្រើប្រាស់ គ្រឿងអេឡិកត្រូនិក នឹងគ្រឿងឧបភោគបរិភោគ... ធ្វើបានក្នុងតម្លៃថោកដែលធ្វើឲ្យទំនិញនៅទីផ្សារសេរីនឹងនៅប្រទេសលោកសេរី មានតម្លៃល្អងាយស្រួលនឹងលក់ដូរ។ដូច្នេះជាង៣០ឆ្នាំមកហើយនេះ ការផ្តួចផ្តើមគំនិតផ្សារសេរីនេះ បានទទួលនូវផលចំណេញផ្នែកសេដ្ឋកិច្ច បានទាំងសងខាង គឺខាងលោកសេរីគេចំណេញខាងលក់ទំនិញបានច្រើនរីឯខាងលោកខាងកើត គឺខាងលោកកុម្មុយនីស្ត ទទួលរូបីយប័ណ្ណចូលពីកាងារពលកម្ម(ចិន វៀតណាម រុស្ស៊ី) ពីការលក់ប្រេងឆៅនឹងឧស្ម័ន(រុស្ស៊ី) ក៏ទទួលបានផលច្រើនដូចគ្នា ក្លាយជាប្រទេសមហាអំណាចសេដ្ឋកិច្ចធំឬតូចទៅតាមមហិច្ឆិតានៃរបបផ្តាច់ការនិមួយៗទាំងនោះ។

មហិច្ឆិតានៃ«របបផ្តាច់ការ»នោះហើយ ដែលធ្វើឲ្យប្រទេសរបស់គេមានការវិវត្តិន៍ផ្ទុយគ្នា ពីខាង«របបលោកសេរី»។ របបផ្តាច់ការគេយកថវិការដែលខាងរោងចក្ររកបាន ទៅធ្វើជាគ្រឿងអាវុធយុទ្ធភ័ណ្ឌចម្បាំង រីឯកម្លាំងពលករទទួលបានកម្រៃតិចតួច គ្រាន់រស់តែមិនអាចធានាអនាគតបានទេ។ ក្នុង១០ឆ្នាំចុងក្រោយនេះ ចិនបានផលិតនាវាចម្បាំង ទាំងរុស្ស៊ីផងខិតខំផលិតកាំជ្រួចនុ្យក្លេអ៊ែរ ខិតខំផលិតអាវុធជីវសាស្ត្រ ទាំងវៀតណាមក៏ដូចគ្នា នាំគ្នាពង្រឹងហេដ្ឋារចនាសម្ព័ន្ធយោធា សម្រាប់ទៅរំលោភដែនសមុទ្រនឹងដែនដី នឹងបូរណភាពនៃប្រទេសជំទៃជិតខាង។ ចំណែកខាងលោកសេរីវិញ គេគិតប្រយោជន៍ពលរដ្ឋជាធំ សេដ្ឋកិច្ចបានរីកចម្រើន គឺពលរដ្ឋជាអ្នកទទួលផលចំណេញ រដ្ឋអំណាចគេខិតខំតែការពារជាតិដោយចងសម្ព័ន្ធយោធា៣២ប្រទេសធ្វើសង្គ្រាមរួមគ្នា ដើម្បីឲ្យមានកម្លាំងខ្លាំងខ្លានឹងឲ្យចំណាយធនធានតិច។ ត្រឹមតែប៉ុណ្ណេះ យើងក៏អាចយល់បានហើយថា អាមេរិកនឹងអឺរ៉ុប នៅតែជាមហាអំណាចសេដ្ឋកិច្ចដ៏រឹងមាំ ក្នុងពីភពលោកដដែល ដោយសារស្ថេរភាពនយោបាយលោកសេរីនោះឯង។

**កម្លាំងសេដ្ឋកិច្ចពិភពលោកបច្ចុប្បន្ន**

សំអាងដោយការមានលុយច្រើន ចិនបានវិនិយោគទៅកេងប្រវ័ញ្ចលើប្រទេសក្រីក្រ ដែលមានមេដឹកនាំផ្តាច់ការ ឲ្យខ្ចីប្រាក់សម្រាប់ធ្វើស្ពានធ្វើថ្នល់ធ្វើសំណង់ធំៗ ហើយបញ្ជូនពលរដ្ឋខ្លួនឲ្យទៅនៅរកស៊ីក្នុងប្រទេសនោះ(កម្ពុជា) គាំទ្រកងទ័ពឲ្យមានរដ្ឋប្រហារ(នៅអាហ្វ្រិក) បំផ្លាញបូរណភាពនៃប្រទេសខ្លះ(នៅអាស៊ី ឬ អឺរ៉ុប)។ ប្រទេសរុស្ស៊ីក៏ដូចគ្នា មានបានហើយ ក៏ទៅរុករានទន្ទ្រានទី ដោយកងកម្លាំងស៊ីឈ្នួល នៅអាហ្វ្រិក នៅមជ្ឈឹមបូព៌ា ទៅឈ្លានពានគេនៅអឺរ៉ុប។ វៀតណាមក៏មិនខុសគ្នាទៅលបឈ្លានពានបូរណភាពរបស់កម្ពុជា ឡាវ ធ្វើឲ្យបាត់បង់ឯករាជ្យភាពរបស់ប្រទេសគេ។

អំពើទាំងនោះបានត្រូវសង្កេតហើយព្រមានដោយប្រទេសលោកសេរី ដែលបានដាក់ទណ្ឌកម្ម ហើយដករោងចក្រខ្លួនចេញពីប្រទេសមហាអំណាចរុស្ស៊ីនឹងចិន ជាបន្តរបន្ទាប់(ប្រធានាធិបតី អាមេរិកាំង ឧណាល ត្រាំ មុនគេដែលបញ្ជាឲ្យដករោងចក្រ ចេញពីប្រទេសចិន ឆ្នាំ២០១៧), ឈប់ទិញឧស្ម័នឬប្រេងឈប់រកស៊ីជាមួយតែម្តង...រងកម្មតែម្យ៉ាងមិនគ្រប់គ្រាន់ ចិនបានរងជម្ងឺឆ្លងកូវីដ១៩ យ៉ាងចាស់ដៃ នៅឆ្នាំ២០១៨ បណ្តាលឲ្យបិទប្រទេសខ្លួនឯងជិត៣ឆ្នាំ... ខាងរុស្ស៊ីវិញ ប្រុងវាយអ៊ុយក្រែនឲ្យបានក្នុងពេល៣ថ្ងៃ តែ២ឆ្នាំកន្លងទៅ នៅតែវាយយកមិនបានសោះ ម្លោះហើយ«ប្រាក់ក៏បង់ចង់ក៏ដាច»ធ្វើសេដ្ឋីពីថ្ងៃមុន បែរជាសេដ្ឋកិច្ចកាន់ដុនដាបទៅៗ អតិផរណាក៏កាន់តែធ្ងន់ធ្ងរ ខិតខំភូតភរមតិសាធារណ ក៏គ្មាននរណាជឿ ដូច្នេះមានតែរត់ទៅប្លន់នៅអាហ្វ្រិក ឬមជ្ឈឹមបូព៌ា ឬអាមេរិកឡាទិន ជាបន្តរទៅទៀតដើម្បីរស់។ វៀតណាមបានរួចពីទណ្ឌកម្មទាំងអម្បាម៉ាននេះ ខុសពីចិននឹងរុស្ស៊ី ពីព្រោះតែបានធ្វើការគាបសង្កត់លើកម្ពុជានឹងឡាវតាមរបៀបលួចលាក់ នឹងការមិនបានរើបំរះពីប្រទេសទាំង២នោះដោយខ្លួនឯងផងដែរ។ បើសេដ្ឋកិច្ចចុះអូនថយហើយ តើហេតុអ្វីបានជាចង់ប្រកាសសង្គ្រាមនុ្យក្លេអ៊ែរ ជាមួយអាមេរិកនឹងអឺរ៉ុប?

**វាសនាអនាគតនៃរបបកុម្មុយនិស្តផ្តាច់ការ**

ប្រទេសដែលមានរបបផ្តាច់ការ តែងគ្រប់គ្រងប្រទេសដោយយោធានឹងប៉ូលីសដើម្បីកេងយកអំណាចរដ្ឋពីប្រជាពលរដ្ឋ

តទៅទំព័រទី១៥

# Analysis of global economic and political developments

From Page 03

easy to sell. So, for more than 30 years, this free-market initiative has been economically profitable on both the liberal side and the communist countries in the East. Labor (China, Vietnam, Russia) from the sale of crude oil and oil (Russia) also get the same benefits to become an economic power, large or small, according to the ambitions of each dictatorship.

It is the ambition of the "dictatorship regime" that has given their countries the opposite evolution from the "liberal regime". Dictatorship regimes use the money the factory earns as weapons, while the low-wage labor force simply cannot guarantee a future. In the last 10 years, China has built warships, both China and Russia have made efforts to build nuclear missiles, Vietnam has made efforts to build biological weapons, and Vietnam has strengthened its military infrastructures to encroach on its territorial waters and territorial integrity.

As for the west, they think of the people, the economy has grown, the people receive the benefits, the governments try to defend 32 countries by tying the military alliances of 32 countries to go for war together, to be stronger and to spend less resources. We understand that America and Europe remain the strongest economic powers in the world due to the liberal political stability of the west countries.

**Current global economic forces**

With a lot of money, China has invested in exploiting poor countries with dictatorial leaders to lend money for bridges, roads, and large structures. And send its citizens to do business in those countries (Cambodia is one of them), support the army for a coup (in Africa), destroy the integrity of some countries (in Asia or Europe). Russia, too, was invaded by mercenaries in Africa, in the Middle East, and invaded Europe. Vietnam is not different from invading the integrity of Cambodia, Laos, losing their independence.

These actions were observed and warned by a liberal country that imposed sanctions and subsequently withdrew its

Please see /15


យើងជឿថា ឆ្នាំល្អបំផុតរបស់អ្នកមកដល់ហើយ
(ឆ្នាំកន្លងទៅ ក៏ល្អសម្រាប់អ្នកដែរ)



Element Care PACE ជួយអ្នកឱ្យរស់នៅដោយឯករាជ្យនៅក្នុងសហគមន៍។
- ការថែទាំសុខភាពតាមបែបវេជ្ជសាស្ត្រ ថែទាំធ្មេញ និងថែទាំភ្នែកផ្ទាល់ខ្លួន ។
- មជ្ឈមណ្ឌលបើកបម្រើនៅពេលថ្ងៃ
មានការដឹកជញ្ជូន មានអាហារ និងសកម្មភាពសង្គម
ទាំងអស់នេះ អ្នកក៏អាចរក្សាសុខភាពល្អបំផុត។

Element Care | PACE

ស្វែងយល់បន្ថែម តើអ្នកឬមនុស្សជាទីស្រឡាញ់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែរឬទេ៖
(877) 803-5564 (TTY 711) ElementCare.org

មិនគិតថ្លៃសម្រាប់អ្នកមានសិទ្ធិទទួលបាន MassHealth និង Medicare ។ សូមទាក់ទងមកយើងសម្រាប់តែ Medicare និងជម្រើសបង់ប្រាក់ដោយខ្លួនឯង។
អ្នកចូលរួមទទួលបានការថែទាំសុខភាពទាំងអស់ សេវាពេទ្យបឋម និងពេទ្យឯកទេស - និងសេវាសង្គ្រោះបន្ទាន់ផ្សេងទៀត ដែលអនុញ្ញាតដោយ PACE ឬទទួលខុសត្រូវទាំងស្រុង និងផ្ទាល់ខ្លួនចំពោះថ្លៃសេវាដែលគ្មានការអនុញ្ញាត។




តមកពីទំព័រទី ០១

# បោះឆ្នោត"ស៊ូព័រធូស្តេយ"នរណាជា

«ស៊ូព័រធូស្តេយ»បានប្រព្រឹត្តទៅនៅថ្ងៃអង្គារទី៥មិនា នៅក្នុងរដ្ឋចំនួន១៥ នៅថ្ងៃជាមួយគ្នា ចំពោះប្រជាពលរដ្ឋនៃគណបក្សធំនិមួយៗ ឲ្យបោះឆ្នោតសម្រេចវាសនាថា«ឲ្យបេក្ខជនឬបេក្ខនារីណាដែលបានឈ្នះដាច់គេឲ្យទៅជា«បេក្ខជនឬបេក្ខនារីប្រធានាធិបតី» ដំណាងគណបក្សប្រជាធិបតេយ្យឬគណបក្សសាធារណរដ្ឋ ឲ្យពលរដ្ឋអាមេរិកាំងជ្រើសរើសឲ្យឡើងជាប្រធានាធិបតីបាននាឱកាសបោះឆ្នោតសាកល នៅថ្ងៃទី៥ខែវិច្ឆិកា២០២៤ខាងមុខ។ថ្មីត្បិតតែបានបេក្ខជនសំខាន់ គឺ ឧណលត្រាំ នឹងជោ បាយដិន ជាគូរប្រកួត ដែលឈ្នះ«ស៊ូពែធូស្តេយ»ដូចការស្មានទុកជាមុនក៏ដោយ ការស្រង់មតិបាននិយាយថា «បេក្ខជនទាំងពីរនោះមានអាយុច្រើនពេកទៅហើយ» ដែលធ្វើឲ្យសហរដ្ឋអាមេរិកនៅតែស្វែងរកដំណោះស្រាយថ្មីសម្រាប់ដំណែងប្រធានាធិបតីតទៅទៀតដដែល, ដូច្នេះ តើអាចនឹងមានអ្វីថ្មីកើតឡើងឬទេនៅមុនថ្ងៃ៥វិច្ឆិកា?

ខាងគណបក្សសាធារណរដ្ឋ លោកអតីតប្រធានាធិបតី ឧណល ត្រាំ បានយកគ្រប់ឈ្នះចំនួនតំណាងរដ្ឋ១៩២៣ លើលោកស្រី នីគី ហៃលី ដែលខិតខំតស៊ូបានរដ្ឋ១ដែរ យ៉ាងស្វិតស្វាញ រហូតដល់ចុងបញ្ចប់។ លោក ត្រាំ អាចចាប់ផ្តើមឃោសនា ជាបេក្ខជនប្រធានាធិបតីខាង«គណបក្សសាធារណរដ្ឋ»បាន ដោយលោក ត្រាំ បានឈ្នះដោយសេចក្តីសម្រេចរបស់តុលាការកំពូល លើបំរ៉ាមតុលាការរដ្ឋកូឡូរ៉ាដូ នឹងរដ្ឋម៉ែន គឺគិតចាប់តាំងពីថ្ងៃទី៦មិនានោះទៅហើយ បើទោះជាលោកនៅជាប់បណ្តឹងផ្សេងទៀតនៅតុលាការច្រើនជាករណីក៏ដោយ, មានករណីខ្លះក៏បានចាញ់ក្តីរួចទៅហើយ តែជាករណីរដ្ឋបវេណីតែប៉ុណ្ណោះ ហើយចំពោះករណីដែលនៅសល់ ធ្វើឲ្យគេសង្ស័យថាលោក ត្រាំ អាចនឹងក្ស័យទុនលំបាកនឹងបន្តរការឃោសនា ពីព្រោះលោកត្រូវជំពាក់ប្រាក់ធានានៅតុលាការចំនួនច្រើនរយលានដុល្លានៅឡើយ។ រីឯគម្រោងនយោបាយរបស់លោក គឺត្រូវបញ្ចប់សង្គ្រាមនៅអ៊ុយក្រែនដោយចងសម្ព័ន្ធភាពជាមួយប្រទេសរុស្ស៊ី ហើយផ្តាច់ជំនួយអាមេរិកទៅឲ្យអ៊ុយក្រែន...ពេលនោះ អាមេរិកនឹងមានកង្វល់តិចតួច សម្រាប់សន្តិសុខសហភាពអឺរ៉ុប ឬសម្រាប់អាស៊ី ឬ សម្រាប់អូសេអានី ...រីឯនយោបាយក្នុងប្រទេសរបស់ ឧណល ត្រាំ គឺការពារអ្នកមានទ្រព្យសម្បត្តិច្រើនឲ្យបង្កើតការងារប្រជាជន,ការពារព្រំដែនមិនឲ្យបរទេសចូលមកក្នុងប្រទេសបាន បណ្តេញជនអន្តោប្រវេសន៍ខុសច្បាប់ចេញពីស្រុក...។ វត្តមានរបស់លោក ត្រាំ ជាបេក្ខជនសាជាថ្មីក៏បានចែកគណបក្សសាធារណរដ្ឋជាច្រើនចំណែកដែរ គឺក្រុមដែលតាមលោក ត្រាំ ប្តូរផ្តាច់គឺជាក្រុមស្តាំផុតនិយម(មានក្រុមណាស៊ី ក្រុមខេខេខេ...) នឹងចេញពីក្រុមដែលនៅខាងបេក្ខជនប្រជែងនឹង ត្រាំ មានឈ្មោះថា«ហ្វើស



អតីតប្រធានាធីបតី Trump នៅមុខក្រចកសេះតុលាការញូយ៉ក ពីរឿងសូកលុយតួរកុនX Stormmy Daniels

First»ពួកគេមានបំណង«មិនឲ្យបោះឆ្នោតទៅលោកត្រាំទេ»គឺក្រុមអភិរក្សនិយមមាន គ្រីស្ទី ឬ នីគី ជាដើម។

ចំណែកខាងគណបក្សប្រជាធិបតេយ្យវិញ លោក ជោ បាយដិន មិនមានគូរប្រជែងទេ លោកឈរឈ្មោះតែម្នាក់ឯងបានឆ្នោតដំណាងរដ្ឋគ្រប់ចំនួន២០៣០ តែទាំងខាងគណបក្សលោកក្តី នឹងទាំងគណបក្សសាធារណរដ្ឋក្តី ទីទានថា«លោកបាយដិន ចាស់ពេក»ក៏បុន្តែ លោកបានបង្ហាញនៅពេលថ្លែងសុន្ទរកថា«State of the Union»កាលពីថ្ងៃទី០៧នៅ«វិមានកាពីតូល»ថាលោកនៅតែមានស្មារតីគ្រប់គ្រាន់ ថាអាចគ្រប់គ្រងប្រទេសបានប្រសើដូចមុន នៅឡើយ។ លោកបន្ទោសសមាជិកសភា ខាងគណបក្សសាធារណរដ្ឋថា«បើអ្នកមិនជួយអ៊ុយក្រែនទេនោះ ពូទីននឹងមិនឈប់នៅត្រឹមអ៊ុយក្រែននោះទេ» សង្គ្រាមអាចនឹងឆេះឆាបអឺរ៉ុប ជាសង្គ្រាមលោកលើកទី៣ផងក៏បាន។ លោក បាយដិន បានរៀបរាប់ពីស្នាដៃលើសេដ្ឋកិច្ច,សង្គមកិច្ចបច្ចេកវិជ្ជាធ្វើឲ្យសហរដ្ឋអាមេរិក ជាប្រទេសមហាអំណាចសេដ្ឋកិច្ច ពុំអាចប្រទេសណាប្រៀបផ្ទឹមបានឡើយ នាឱកាសដែលលោកកាន់អំណាច អតិផរណាបានធ្លាក់ចុះទាប កាងារបានកើនឡើង ប្រជាពលរដ្ឋទទួលប្រាក់ចំណូលច្រើនជាងមុន ចំណាយសុខភាពសាធារណៈ ក៏ធ្លាក់ចុះទាបជាងមុនដែរ។

ហេតុការដែលថាបេក្ខជនទាំង២«ចាស់ពេក»នោះ ក្រុមអ្នក«គ្មានគណបក្ស»មួយក្រុម កំពុងរួបរួមដៃគ្នាបង្កើតជាគណបក្សមួយថ្មីទៀត ដែលមានឈ្មោះថា«ក្រុមគ្មានផ្លាក»ជាអ្នកនយោបាយមានវ័យក្មេង មានបំណងឈរឈ្មោះឲ្យអ្នកបោះឆ្នោតមានជម្រើសថ្មីមួយទៀត ក្រុមនោះអាចនឹងមានប្រជាប្រិយភាពរហូតដល់រំខានបេក្ខជន«អាយុច្រើន»ទាំង២បាន។

នៅមានការជ្រៀតជ្រែកពីបរទេស ស្តីពីឃោសនាសម្ងាត់របស់ប្រទេសរុស្ស៊ី តាមបច្ចេកវិជ្ជាទំនើប កាលពីជំនាន់គូរប្រជែង ហ៊ីឡារី គ្លីងតុន នឹង ឧណល ត្រាំ, មេរៀននោះបានត្រូវគេការពារជាប់នៅជំនាន់ គូរប្រជែង ត្រាំ នឹង បាយដិន ដែលជាហេតុធ្វើឲ្យត្រាំចាញ់ឆ្នោតយ៉ាងក្តៅក្រហាយ។លើកក្រោយនេះក្តី គេនឹងការពារតទៅទៀត យ៉ាងតឹងរ៉ឹង។

គេនៅចងចាំរឿងមួយទៀត ដែលកាលពីពេលបោះឆ្នោត ត្រាំ នឹង បាយដិន លើកមុនដែរ គឺក្រុមសាសនាគ្រឹស្តខាងគណបក្សសាធារណរដ្ឋខ្លួនឯងបានឃោសនាប្រឆាំងនឹងលោក ត្រាំ យ៉ាងខ្លាំងខ្លា ដោយគេបារម្ភខ្លាច ត្រាំ ឈ្នះឆ្នោតម្តងទៀត ពីព្រោះគេយល់ថាលោក ត្រាំ មិនប្រកាន់នយោបាយតាមទ្រឹស្តីនៃសាសនាគ្រឹស្ត ដែលក្រុមអ្នកសាធារណរដ្ឋធ្លាប់ប្រកាន់យកនោះទេ ពួកនោះគឺជាសហគមន៍ដ៏ធំមួយ នៅសហរដ្ឋអាមេរិក ដែលអាចនឹងប្រកាន់ជំហរដដែលនៅថ្ងៃ៥វិច្ឆិកា២០២៤ខាងមុខ។

រឿងដែលមិនគួរជឿទើបតែនឹងផុះឡើង គឺរឿងក្តីព្រហ្មទណ្ឌចំនួន៤ ដែលនៅជាប់នឹងខ្លួនលោកត្រាំហើយដែលលោក ត្រាំ កំពុងតែស្វែងរកការពន្យាពេលកាត់ទោស, ជាពិសេសករណីសូកលុយបំបិទមាត់ រឿងអាស្រូវផ្លូវភេទមួយជាមួយនារីលក់ខ្លួន ពេលខ្លួនទើបរៀបការជាមួយភរិយានាង មេឡានី រឿងក្តីនោះនឹងឡើងមកដល់ នៅខែមេសានេះហើយ...ត្រាំ ទំនងជាអស់ផ្លូវដើរហើយ។

នៅក្នុងការស្ទង់មតិចុងក្រោយរបស់«រ៉យទ័រ/អ៊ីពសូស» ការបោះឆ្នោតនៅថ្ងៃទី៥វិច្ឆិកាខាងមុខ ត្រាំ នឹងចាញ់ បាយដិន តែមួយពិន្ទុតែប៉ុណ្ណោះ គឺជាការប្រកួតយ៉ាងប្រកៀកគ្នាជាទីបំផុត, លោកត្រាំ សំអាងទៅលើមូលដ្ឋានដ៏មាន«ភក្តីភាពនឹងដាច់ខាត»របស់គាត់ ដែលមានប្រមាណ៣០ទៅ៣៥% ដូច្នេះតម្រូវឲ្យរកអ្នកបោះឆ្នោតបន្ថែមឲ្យបាន១៥ទៅ២០%ទៀត ដែលជាការដ៏លំបាកមួយ ពីព្រោះអ្នកដែលនៅសល់ទាំងនោះ សុទ្ធតែគេចង់ទាត់លោកត្រាំចោល ដោយស្ទើរតែគ្រប់ការវិភាគ នៃអ្នកជំនាញការទាំងអស់ សំដែងថា«លោក ត្រាំ ជាប្រធានាធិបតីដែលអាក្រក់ជាងគេទាំងអស់ ក្នុងចំណោមប្រធានាធិបតីទាំង៤៥»។

ចំណែកលោកបាយដិនវិញ មានការខាតបង់ដោយសារតែមានអាយុច្រើនមែនតែមានផលចំណេញដោយមានអ្នកប្រជែងតិចតួច មានអ្នកប្រឆាំងនឹងនយោបាយលោកក៏តិចតួច ជាពិសេសនឹងមានឆ្នោតនៃ«អ្នកដែលប្រឆាំងដាច់ខាតនឹងលោកត្រាំ»វិញដែរ មកនៅខាងលោក ដូចជាក្រុមបោះឆ្នោតឲ្យ ណីគី ហៃលី, គ្រីស្ទី នឹង សង់ទី ជាដើម ជាពិសេស លោកអតីតអនុប្រធានាធិបតីរបស់ ត្រាំ គឺលោក ម៉ាយ ផិន និយាយថា នឹងមិនបោះឆ្នោតឲ្យ ត្រាំ ទេ នៅខែវិច្ឆិកាខាងមុខ។ចំណែកឯថវិកាឃោសនារបស់លោក បាយដិន បានកើនឡើងឈ្នះលោក ត្រាំ ដាច់ស្រឡះ ដែលជាសញ្ញាមួយដែរថា បាយដិនមានអ្នកគាំទ្របេក្ខភាពច្រើនជាង ត្រាំ បាន ៕

Lowell
Primary Care Center
មណ្ឌលថែទាំសុខភាព Lowell
1075 Westford Street, Unit 204
Lowell, MA 01851 • (978) 455-7992

Lynn
Primary Care Center
មណ្ឌលថែទាំសុខភាព Lynn
280 Union Street, Unit 402
Lynn, MA 01901 • (781) 780-7755


Chhan Touch, FNP-BC
ឆាន់ ទូច


Practice Manager
Channa Khan, CMA
អ្នកគ្រប់គ្រងគ្រូពេទ្យ
ចាន់ណា ខាន់


Sophor Chhour, LMHC
សុភ័រ ឈួ


Nalyne Dom, FNP-BC
ណាលីន ដំ


Nida Lam, FNP-BC
នីដា ឡាម


Maredy Sar, DNP, NP-C
ម៉ារីឌី ស


Miadette Pheng-Phal, DNP, NP-C
មីយ៉ាដេត ផេងផល

Now Accepting New Patients
ឥឡូវនេះ បើកទទួលអ្នកជំងឺថ្មី

Family Medicine
ថែទាំសមាជិកគ្រួសារ

Behavioral Health
ថែទាំសុខភាពផ្លូវចិត្ត

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer

យើងទទួល MassHealth Medicare និងការធានារ៉ាប់រងសុខភាពផ្សេងៗ
បុគ្គលិករបស់យើងនិយាយភាសាខ្មែរ




# ការចាប់ខ្លួន ការចាប់ដាក់គុក និងការស្លាប់មនុស្សជាច្រើននាក់ បន្ទាប់ពីការបណ្តេញចេញដោយបង្ខំរបស់រដ្ឋាភិបាលក្នុងខេត្តព្រះវិហារ ប្រទេសកម្ពុជា

**ដោយ: សុបិន អ៊ុង កាសែត Khmer Post USA**

ស្ត្រីម្នាក់អាយុ៥៣ឆ្នាំបានធ្វើអត្តឃាតកាលពីថ្ងៃទី១៥ខែមីនាបន្ទាប់ពីកងកម្លាំងរដ្ឋាភិបាលបានបណ្តេញអ្នកភូមិដោយហិង្សានៅស្រុកគូលែនខេត្តព្រះវិហារភាគខាងជើងនៃប្រទេសកម្ពុជា។

របាយការណ៍ចេញផ្សាយដោយអង្គការ លីកាដូ កាលពីថ្ងៃទី៦ ខែមីនាបានឲ្យដឹងថា "កងកម្លាំងប្រដាប់អាវុធចម្រុះមួយក្រុម រួមទាំងមន្ត្រីអាវុធហត្ថនិងមន្ត្រីនគរបាលអមដោយមន្ត្រីរដ្ឋបាលព្រៃឈើ បានប្រមូលផ្តុំគ្នានៅព្រឹកនេះដើម្បីទន្ទ្រានយកដីមានជម្លោះក្នុងខេត្តព្រះវិហារ ដែលបណ្តាលឱ្យមានការប្រើប្រាស់ គ្រាប់រំសេវ និងការចាប់ខ្លួន។ របាយការណ៍រាយការណ៍ថា កម្លាំងចម្រុះប្រដាប់ដោយកាំភ្លើងស្វ័យប្រវត្តិបានចូលជាមួយត្រាក់ទ័រដើម្បីឈូសឆាយដីជម្លោះ។ អ្នកភូមិដែលរស់នៅក្នុងតំបន់ដោយមានការភ័យខ្លាចការបណ្តេញចេញដោយបង្ខំ និងទ្រព្យសម្បត្តិរបស់ពួកគេត្រូវបានបំផ្លាញ បានប្រមូលផ្តុំគ្នាទាមទារឱ្យកម្លាំងរដ្ឋាភិបាលចាកចេញពីតំបន់នោះដែលនាំឱ្យមានការប្រឈមមុខដាក់គ្នា។ វីដេអូមួយដែលថតបានគ្រាប់រំសេវត្រូវបានបាញ់ម្តងហើយម្តងទៀតដោយអាជ្ញាធរ បន្ថែមទាំងការប្រើប្រាស់គ្រាប់បែកផ្សែង។

ជាលទ្ធផល មនុស្សចំនួន ៤០នាក់ត្រូវបានបញ្ជូនទៅសាលាដំបូងខេត្តព្រះវិហារ ២៨ នាក់ កំពុងជាប់ពន្ធនាគារ ខណៈមនុស្ស ៣០នាក់ រួមមានស្ត្រី និងកុមារតូចៗ បានរត់គេចខ្លួន និងស្នាក់នៅក្នុងព្រៃ ដើម្បីជៀសវាងការចាប់ខ្លួនដាក់ពន្ធនាគារ។ ស្ត្រីម្នាក់ដែលនៅក្នុងភូមិបាន ប្រាប់ សារព័ត៌មាន VOD ជាឯកច្ឆ័ន្ទនៅថ្ងៃទី១៦ ខែមីនា ថា "គ្មានអ្វីឈឺចាប់ជាងនេះទេ ពេលឃើញផ្ទះយើងត្រូវភ្លើងឆេះ ហើយគេតាមប្រមាញ់យើង" បុរសម្នាក់ទៀតនិយាយថា "ស្លាប់ក៏ប្រសើរជាងគេយកដីយើងទាំងអស់ រស់គ្មានន័យទៀតទេ"។ ក្រុមនេះបានស្នាក់នៅក្នុងព្រៃអស់រយៈពេល ១០ ថ្ងៃដោយគ្មានអាហារ ឬទឹក គ្មានមុង កុមារខ្លះកើតជំងឺគ្រុនចាញ់។ ស្ត្រីម្នាក់បាននិយាយថា ពួកគេនឹងធ្វើអត្តឃាតជាក្រុមប្រសិនបើមិនមានដំណោះស្រាយនៅថ្ងៃខាងមុខ។

ឧប្បត្តិហេតុនេះជាជម្លោះដីធ្លីមួយក្នុងចំណោមជម្លោះដីធ្លីជាបន្តបន្ទាប់ជាច្រើនដែលបណ្តាលមកពីគោលនយោបាយសម្បទានដីសេដ្ឋកិច្ចរបស់រដ្ឋាភិបាល។ ឧបទ្ទវហេតុពិសេសនេះពាក់ព័ន្ធនឹងក្រុមហ៊ុន Seladamex Co., Ltd. ដែលក្រុមហ៊ុនបានទទួលសម្បទានដីសេដ្ឋកិច្ចក្នុងឆ្នាំ ២០១១ នៅឃុំស្រវ៉ាង និងឃុំភ្នំត្បែងពីរ ស្រុកគូលែន ខេត្តព្រះវិហារ។ ដីសម្បទាននេះបានបង្កើតជម្លោះដីធ្លី


Cambodian armed force and forest authorities fired weapons and arrested the villagers during force evictions in Preah Vihea Province

ជាមួយប្រជាពលរដ្ឋរាប់រយគ្រួសារដែលរស់នៅក្នុងតំបន់នោះ។ ក្នុងឆ្នាំ ២០២២ មានតែ ១៣១ គ្រួសារបានរាយការណ៍


ប្រជាពលរដ្ឋនាំគ្នាអុជធូបបួងសួងសុំកុំអោយអាជ្ញាធរដេញពួកគាត់ចេញលើដីជម្លោះ

ថា ទ្រព្យសម្បត្តិ និងដំណាំរបស់ពួកគេត្រូវបានបំផ្លាញដោយអាជ្ញាធរក្នុងនាម

**តទៅទំព័រទី២០**

# Multiple Arrests, Imprisonment, and Death After Government Forced Evictions in Preah Vihea, Cambodia

**By Soben Ung, Khmer Post USA**

A woman, age 53, committed suicide on March 15 after government forces violently evicted villagers in the Kuleaen district, Preah Vihea province in northern Cambodia.

A report published by LICADO, a rights advocate group, on March 6 said "a group of mixed armed forces including gendarmes and police officers accompanied by forestry administration officials mobilized this morning to secure disputed land in the Preah Vihear province, resulting in the use of live ammunition and arrests." It was reported that a mixed force armed with automatic rifles entered with tractors to clear the disputed land. Villagers living in the area, afraid of forced eviction and their property being destroyed, gathered to demand the government force leave the area which resulted in a confrontation. A video captured live ammunition being shot repeatedly by the authorities in addition use of smoke grenades.

As results, 40 people were sent to Preah Vihear Provincial Court, 28 people are in prison, while 30 people including women and small children escaped and stayed in the forest to avoid arrest and imprisonment. One woman remaining unanimous told VOD on March 16, "nothing is more painful to see our homes have been burned and they are hunting us down" Another man said, "it's better to die anyway, they took all our land, there is no meaning to live anymore." The group stayed in forest for 10 days without foods or water, no mosquitoes net, some children developed malaria. A woman said that they will commit suicide as a group if there is no solution in the coming days.

This incident is one of many long series of land conflicts resulted in Economic Land Concession policy by the government. This particular incident involves Seladamex Co., Ltd., the company was granted an Economic Land Concession in 2011 in Sravang and Phnum Tbaeng Pir communes in Preah Vihear's Kuleaen district. The land concession created land conflicts with hundreds of families who already live in that area. In 2022 alone, 131 families reported that their belongings and crops had been destroyed by the authorities on behalf of the company, according to the LICADO report.

The used of an armed force to violently evict villagers reminded many Cambodians of the Boeung Kak Lake community in Phnom Penh in 2008, fatal violence was also used to forcibly evict local residents and clear the way for tourist development. And in 2007, two people were shot dead by security forces while evicting residents near the Preah Vihear temple complex in northern Cambodia.

Record showed that over 2.25 million hectares (or 5.56 million acres) of

**Please see /20**

# អ្នកស្រាវជ្រាវនិយាយថា បឹងទន្លេសាបមានសារសំខាន់សម្រាប់ប្រទេសកម្ពុជា “ប្រក្រតីភាពថ្មី មានភាពមិនប្រាកដប្រជា”

រូបឯកសារ៖ ប្រជាជនទិញត្រីនៅច្រាំងទន្លេសាបក្នុងរដូវប្រមូលផលត្រី នៅភូមិទួលអំពិល

ជាយក្រុងភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី ២ ខែ មករា ឆ្នាំ ២០២៣។

ទីក្រុងវ៉ាស៊ីនតោន និងភ្នំពេញ —

ការប្រែប្រួលអាកាសធាតុ និងទំនប់ទឹកដែលភាគច្រើនគ្រប់គ្រងដោយប្រទេសចិនកំពុងគំរាមកំហែងបឹងទន្លេសាបដ៏ធំសម្បើមរបស់កម្ពុជា និងសហគមន៍ជុំវិញបឹង ដោយធ្វើឱ្យការផ្គត់ផ្គង់ប្រូតេអ៊ីនរបស់ជាតិ និងប្រព័ន្ធអេកូឡូស៊ីទន្លេមេគង្គកាន់តែមានហានិភ័យ។

រយៈពេលបីឆ្នាំជាប់គ្នា ចាប់ពីឆ្នាំ ២០១៩-២០២១ គឺស្ងួតហួតហែងបំផុតក្នុងកំណត់ត្រា។ ជីពចរទឹកជំនន់ដ៏សំខាន់របស់បឹងទន្លេសាបហាក់ដូចជាកំពុងលែងដំណើការរួមជាមួយនឹងស្តុកត្រីដ៏ច្រើនសន្ធឹកសន្ធាប់របស់បឹង។ ជាធម្មតាទឹកហូរចូលបឹងទន្លេសាបរយៈពេល ១២០ ថ្ងៃក្នុង រដូវវស្សា មានបរិមាណកើនឡើងច្រើនដល់ទៅ ៦ ដង មុនពេលហូរចូលទៅក្នុងទន្លេមេគង្គវិញ នៅពេលដែលរដូវវស្សាបញ្ចប់ ជាធម្មតានៅចុងខែកញ្ញា។ ភាពប្រែប្រួលនេះ គឺជាជីពចរ។

ខណៈពេលដែលរយៈពេលពីរឆ្នាំចុងក្រោយនេះ មានភ្លៀងធ្លាក់កាន់តែ



អ្នកនេសាទយកត្រីមកលក់នៅផ្សារ

តទៅទំព័រទី១១

# For Cambodia's Crucial Tonle Sap Lake, 'New Normal is Uncertainty,' Researchers Say

WASHINGTON AND PHNOM PENH —

Climate change and upstream dams, most of them controlled by China, are threatening Cambodia's enormous Tonle Sap Lake and its surrounding communities, putting the nation's protein supply and the greater Mekong River ecosystem at risk.

The three-year stretch from 2019-2021 was the driest on record. The Tonle Sap's vital flood pulse appeared to be dying, along with much of the lake's bountiful fish stocks. Water typically flows into the Tonle Sap Lake for 120 days during the wet season, swelling it as much as six-fold before running back into the Mekong River as the rainy season ends, usually in late September. This fluctuation is the pulse.

And while the past two years have seen more rainfall, a nearly normal wet-season lake expansion and the usual reversed flow, such temporary relief cannot offset the long-term effects of a lake in crisis, experts and officials told VOA Khmer.

"The new normal is uncertainty," said Brian Eyler, who directs the Stimson Center's programs on Southeast Asia and energy, water and sustainability. "That the predictability of a traditional expansion happening nearly every wet season, or every monsoon season, cannot be relied upon." The Stimson Center is in Washington.

Fears of the ecosystem dying out

Please see /11








តមកពីទំព័រទី ១០

# អ្នកស្រាវជ្រាវនិយាយថា បឹងទន្លេ...

ច្រើន ការពង្រីកបឹងនៅរដូវវស្សាស្ទើរតែធម្មតា និងលំហូរបញ្ច្រាសធម្មតា ការសង្គ្រោះបណ្តោះអាសន្នបែបនេះ មិនអាចទូទាត់ផលប៉ះពាល់រយៈពេលវែងនៃបឹងដែលមានវិបត្តិនោះទេ នេះបើតាមអ្នកជំនាញ និងមន្ត្រីបានប្រាប់ VOA ខ្មែរ។

លោក Brian Eyler ដែលដឹកនាំកម្មវិធីរបស់មជ្ឈមណ្ឌល Stimson ស្តីពីអាស៊ីអាគ្នេយ៍ និងថាមពល ទឹក និងនិរន្តរភាពបាននិយាយថា "ប្រក្រតីភាពថ្មី គឺភាពមិនប្រាកដប្រជា" ។ "ថាការព្យាករណ៍នៃការពង្រីកបែបប្រពៃណីកើតឡើងស្ទើរតែគ្រប់រដូវវស្សា ឬរដូវមូសុងមិនអាចពឹងផ្អែកបានទេ"។

ការភ័យខ្លាចនៃប្រព័ន្ធអេកូឡូស៊ីនឹងបាត់បង់ជីវិតបានទាក់ទាញការចាប់អារម្មណ៍ពីអន្តរជាតិដោយបានចាត់ទុកបឹងទន្លេសាបថា ជាជលផលនេសាទក្នុងទឹកដែលមានផលិតភាពបំផុតរបស់ពិភពលោក និងជាប្រភពនៃប្រូតេអ៊ីនភាគច្រើនដែលប្រជាជនកម្ពុជាប្រើប្រាស់។

ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ បឹងទន្លេសាបបានឈានដល់លំហូរសរុបស្ទើរតែធម្មតា នេះបើយោងតាមគម្រោងត្រួតពិនិត្យទំនប់វារីអគ្គិសនីមេគង្គរបស់មជ្ឈមណ្ឌល Stimson។ ទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ ២០២២ លំហូរទឹកភាគច្រើន បានមកដល់យឺតក្នុងរដូវវស្សា ដោយសារមានភ្លៀងធ្លាក់ខ្លាំងមានន័យថាបឹងនេះ មិនមានលំហូរទឹកចូលនៅដើមរដូវដែលផ្ទុកដីល្បាប់ កម្អែ និងសារធាតុចិញ្ចឹមសំខាន់ៗសម្រាប់ស្តុកត្រីប្រចាំឆ្នាំ។

កាលពីឆ្នាំមុន បានឃើញលំហូរទឹកប្រចាំខែជាកម្រិតមធ្យមជាប្រវត្តិសាស្ត្រ បង្កើតបានរដូវនេសាទសមរម្យ នេះបើយោងតាមគម្រោង Stimson ។ ទិន្នន័យពីរដ្ឋបាលជលផលកម្ពុជាបង្ហាញថា ត្រីទឹកសាបចំនួន ៤១៣២០០តោន ត្រូវបានចាប់ក្នុងឆ្នាំ ២០១៩ បន្ទាប់មក ៣៨៣០៥០ នៅឆ្នាំ ២០២១ និងត្រឹមតែ ៣៦៨០៥៩ ក្នុងឆ្នាំ ២០២២។ អ្នកនាំពាក្យជលផលបានប្រាប់ VOA ថា ត្រីទឹកសាបចំនួន ៤២៦៧៥០ តោនត្រូវបានចាប់ មួយតោនស្មើនឹង ១០០០ គីឡូក្រាម។

"សម្រាប់ពេលនេះ ប្រព័ន្ធអេកូឡូស៊ីនៃទន្លេមេគង្គហាក់ដូចជា ... មិនដូចពីមុនទេ ប៉ុន្តែវានៅតែមាន។ វាមិនទាន់ងាប់ទាំងស្រុងទេ" នេះបើតាម Eyler បាននិយាយកាលពីខែមករាក្នុងអំឡុងពេលសម្ភាសន៍តាម Zoom ។

អ្នកត្រួតពិនិត្យទំនប់វារីអគ្គិសនីមេគង្គកំពុងតាមដានកន្លែងប្រភពលំហូរទឹក កន្លែងដែលទឹកឈប់លែងហូរនៅផ្នែកខាងលើ និងរបៀបដែលការសម្រេចចិត្តដែលធ្វើឡើងដោយប្រទេសនីមួយៗកំពុងប៉ះពាល់ដល់ប្រទេសជិតខាងផ្សេងទៀត។

យោងតាមទិន្នន័យរបស់ខ្លួន លំហូរទឹកសរុបចូលទៅក្នុងបឹងទន្លេសាបនឹងខ្ពស់ជាង ១២.៤% នៅក្នុងខែកញ្ញា នៅពេលដែលវាឈានដល់កំពូលឆ្នាំ ២០២៣ ប្រសិនបើវាមិនមែនសម្រាប់



**FILE - People buy fish at the bank of the Tonle Sap river during the fish harvesting season in Toul Ampil village on the outskirts of Phnom Penh, Cambodia, Jan. 2, 2023.**

ទឹកដែលត្រូវបានរក្សាទុកនៅផ្នែកខាងលើទេ ដែលភាគច្រើននៅក្នុងអាងស្តុកទឹករបស់ចិន។

យោងតាមគម្រោងត្រួតពិនិត្យនេះ បានឱ្យដឹងថា ប្រទេសចិនក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះ ហាក់ដូចជាបានទប់ទឹកតិចជាងមុន បើធៀបនឹងឆ្នាំមុនៗ។ ប៉ុន្តែវាមិនទាន់ច្បាស់ថាតើនោះមកពីចិនឆ្លើយតបទៅនឹងកង្វល់ពីសហគមន៍ខាងក្រោម ឬដោយសារតែតម្រូវការរបស់ចិនតិចជាងមុន នេះបើយោងតាមគម្រោងមជ្ឈមណ្ឌល Stimson ។

បាតុភូតមួយដែលអ្នកស្រាវជ្រាវមជ្ឈមណ្ឌល Stimson កំពុងពិនិត្យមើលយ៉ាងជិតដល់ គឺរបៀបដែលរដូវវស្សាកំពុងផ្លាស់ប្តូរ។ ទឹកឡើងមកដល់យឺត និងស្រកយូរជាងបទដ្ឋានប្រវត្តិសាស្ត្រ ជាការឆ្លុះបញ្ចាំងថា អាចបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

លោក Alan Basist ប្រធានអង្គការ Eyes on Earth និងជាសហអ្នកស្រាវជ្រាវនៃក្រុមហ៊ុន ត្រួតពិនិត្យទំនប់ទន្លេមេគង្គ (Mekong Dam Monitor) ក្នុងអំឡុងពេលសម្ភាសន៍ខែមករាបានបន្តថា៖ "ប្រសិនបើវាពិត ហើយយើងអាចបញ្ជាក់បាន នោះ

តទៅទំព័រទី២៤

# For Cambodia's Crucial Tonle Sap Lake, 'New Normal is Uncertainty,' Researchers Say

From Page 10

have drawn international attention, given the Tonle Sap's distinction as one of the world's most productive inland fisheries — and as the source of most of the protein consumed by Cambodians.

Over the past two years, Tonle Sap Lake has reached nearly normal total flow, according to the Stimson Center's Mekong Dam Monitor project. However, in 2022 much of that flow came later in the wet season due to heavy rainfall, meaning the lake missed out on the early-season inflows that carry sediment, larva and nutrients crucial to annual fish stocks.

Last year saw monthly flows nearly track historical averages, which produced a decent fishing season, according to the Stimson project. Data from Cambodia's Fisheries Administration show 413,200 metric tons of freshwater fish were caught in 2019, then 383,050 in 2021 and just 368,059 in 2022. A Fisheries spokesperson told VOA Khmer that 426,750 metric tons of freshwater fish were caught in 2023. Each metric ton equals 1,000 kg.

"For now, the ecosystem of the Mekong seems to be … not like it was before, but it's still there. It hasn't completely died out," Eyler said in January during an interview on the Zoom platform.

The Mekong Dam Monitor is seeking to track where flow originates, where it is being stopped upstream, and how the decisions made by each of the countries are affecting the other nearby nations.

According to its data, the total flow into the Tonle Sap would have been 12.4% higher in September, when it reached its 2023 peak, if it weren't for water being withheld upstream, mostly in Chinese reservoirs.

China in the past two years appears to have withheld less water, compared with previous years, according to the monitoring project. Yet it's unclear if that's because it is responding to the concerns from downstream communities or because its needs were less, according to the Stimson project.

One phenomenon the Stimson researchers are watching closely is how the wet season is changing. It is arriving later and lasting longer than historical norms, a possible reflection of climate change.

"If indeed that's true, and [if] we can substantiate it, then there's reason for the dams upstream not to hold water back at the beginning of the wet season, and to hold water back at the end of the wet season," said Alan Basist, president of Eyes on Earth and a co-lead researcher of the Mekong Dam Monitor, during the January interview.

The Chinese Embassy in Washington said the "rational development" of the Mekong, which China calls the Lancang River, is in the overall interest of all countries that depend on it.

"China always attaches great importance to the concerns and needs of the countries downstream, maintains close communication with them, commits itself to carrying out cooperation on water resources with relevant countries such as sharing hydrological data and flood control and drought relief," said embassy spokesperson Liu Pengyu in an email on February 26.

The Mekong River Commission (MRC) is the main regional body tasked with bringing countries together to coordinate water management and consult on potential new dam projects on the massive river and its tributaries.

In 2020, the MRC attributed the delayed swelling to lower 2019 rainfall and operations of upstream Mekong hydropower dams, two of which are in Laos and 11 in China.

But the MRC Secretariat said in an email to VOA Khmer in February that it was too soon to know what the "new normal" looks like, given recent droughts and "human activities in the

# ការអំពាវនាវកើនឡើង ដើម្បីយកដីត្រឡប់មកវិញ ដែលត្រូវបានរំលោភយកតាមគោលនយោបាយ ស្តីពីសម្បទានដីសេដ្ឋកិច្ចរបស់កម្ពុជា

by Gerald Flynn on 8 November 2023

MONGABAY

• ការគ្រប់គ្រងដីធ្លីនៃប្រទេសកម្ពុជាមិនត្រឹមត្រូវដោយពួកឥស្សរជនក្រោមគោលនយោបាយសម្បទានដីសេដ្ឋកិច្ច បានជម្លៀសប្រជាជននៅតាមជនបទរាប់ពាន់គ្រួសារ ស្មើនឹង ៤០% នៃការកាប់បំផ្លាញព្រៃឈើសរុប។

• រដ្ឋាភិបាលហាក់បីដូចជាទទួលស្គាល់នូវភាពគ្មានប្រសិទ្ធភាពនៃគោលនយោបាយសម្បទានដីសេដ្ឋកិច្ច (ELCs) ជាកត្តាជំរុញសេដ្ឋកិច្ច ការអំពាវនាវកំពុងកើនឡើងដើម្បីប្រគល់ដីដែលត្រូវបានដកហូតទៅឲ្យសហគមន៍ ឬយកមកវិញសម្រាប់គោលបំណងផ្សេងទៀត។

• អ្នកជំនាញម្នាក់និយាយថាតួនាទីរបស់សហគមន៍មូលដ្ឋាននឹងជាចំណុចស្នូលនៃភាពជោគជ័យនៃកំណែទម្រង់ប្រព័ន្ធ ELC ហើយនឹងត្រូវគិតគូរយ៉ាងម៉ត់ចត់ដើម្បីបញ្ចៀសបញ្ហាប្រព័ន្ធចាស់។

• សំណើមួយទៀត គឺត្រូវផ្តល់ដីធ្លីដែលបច្ចុប្បន្នកាន់កាប់ដោយ ELCs ដែលមិនដំណើរការទៅឱ្យសហករណ៍កសិកម្មដែលគ្រប់គ្រងដោយសហគមន៍ ដោយដាក់អំណាចចរចាបន្ថែមទៀតនៅក្នុងដៃរបស់កសិករជាជាងសម្បទាន។

ភ្នំពេញៈ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងក្នុងពិធីសម្ពោធរោងចក្រចម្រាញ់ស្ករស នៅខេត្តកំពង់ស្ពឺ កាលពីឆ្នាំ ២០១២ ថា "ធ្វើឱ្យថៅកែក្លាយជាអ្នកមាននៅកម្ពុជា"។ "បើប្រទេសមួយគ្មានសេដ្ឋី តើអ្នកក្រអាចយកលុយពីណា?"

នេះបានគូសបញ្ជាក់អំពីមនោគមវិជ្ជាដែលជាបេះដូង នៃគោលនយោបាយសម្បទានដីសេដ្ឋកិច្ច ឬ ELCs ដែលសន្យាអត្ថប្រយោជន៍សម្រាប់ទាំងអស់គ្នា ដោយការប្រគល់ប្រទេសដ៏ច្រើនសន្ធឹកសន្ធាប់ដល់ឥស្សរជនមួយក្តាប់តូចដើម្បីអភិវឌ្ឍភាគច្រើនសម្រាប់កសិឧស្សាហកម្ម។

រោងចក្រចម្រាញ់ស្ករសដែលលោក ហ៊ុន សែន ថ្លែងសុន្ទរកថានេះគឺជារបស់ទីប្រឹក្សាជិតស្និទ្ធបំផុតរបស់គាត់គឺលោក លី យ៉ុងផាត់ ដែលជាព្រឹទ្ធសមាជិកបក្សកាន់អំណាចដែលមានអាណាចក្រជំនួញដ៏ធំទូលាយ និងជាប់ក្នុងឯកសារជាប្រវត្តិសាស្ត្រនៃការបំផ្លិចបំផ្លាញបរិស្ថាន។

រោងចក្រចម្រាញ់ស្ករសរបស់សមាជិកព្រឹទ្ធសភា និង ELCs ដែលគាត់ត្រូវបានផ្តល់អោយសម្រាប់ការអភិវឌ្ឍន៍ចំការ ឥឡូវនេះនៅស្ងៀមស្ងាត់ឈឹង។ ប្រព័ន្ធអេកូដែលមិនអាចជំនួសបាន ដែលធ្លាប់កាន់កាប់ ELCs របស់ លី យ៉ុងផាត់ ត្រូវបានបាត់បង់ជាយូរមកហើយ។

# Calls grow to repurpose land squandered in Cambodia's concession policy

by Gerald Flynn on 8 November 2023

MONGABAY

- *The mismanagement of large swaths of Cambodia's land by the country's elites under the policy of economic land concessions has displaced thousands of rural families and accounted for 40% of total deforestation.*
- *With even the government seeming to acknowledge the ineffectiveness of ELCs as an economic driver, calls are growing to return the land to dispossessed communities or repurpose them in other ways.*
- *One expert says the role of local communities will be central to the success of any reformation of the ELC system and will need to be carefully considered to avoid the pitfalls of the old system.*
- *Another proposes giving land currently owned by nonperforming ELCs to agricultural cooperatives managed by communities, placing more negotiating power in the hands of farmers rather than concessionaires.*

PHNOM PENH — "Make the bosses rich in Cambodia," then-prime minister Hun Sen said at the 2012 inauguration of a sugar refinery in Kampong Speu province. "If a country has no millionaires, where can the poor get their money from?"

This underscored the ideology at the heart of the policy of economic land concessions, or ELCs, which promised benefits for all by handing vast swaths of the country to a handful of elites to develop, mostly for agroindustry.

The sugar refinery where Hun Sen gave this speech belonged to one his closest advisers, Ly Yong Phat — a ruling party senator with a sprawling business empire and a well-documented history of environmental vandalism.

The senator's sugar refineries and the ELCs he was granted for the development of plantations now sit dormant and fallow. The irreplaceable ecosystems that once occupied Ly Yong Phat's ELCs are long gone.

So are the thousands of families who were evicted to make way for the plantations. While many of the evictees temporarily found day-laborer work on the plantations, there was no compensation for the family farms that were lost. Then, when Cambodia's sugar business became embroiled in the so-called Blood Sugar scandal — an advocacy campaign that targeted European buyers and Australian financiers of Cambodian sugar due to rights abuses linked to tycoons like Ly Yong Phat — the refineries unceremoniously fell silent, leaving former residents with no land and no work.

This is just one example of the countless social, environmental and economic failings of Cambodia's ELC system, which culminated in May 2012, when the government issued an order banning the issuance of new ELCs. However, even today, concessionaires still control some 2.25 million hectares (5.56 million acres) of Cambodia — roughly 14% of the country, or the size of the state of New Jersey — through 313 ELCs, according to data compiled by rights group Licadho.

Please see /13



In December 2022, a fire burned through a forest within the 9,059-hectare Chinese-owned Great Field economic land concession in Kampong Speu province. Image by Andy Ball / Mongabay.



In February 2023, timber was frequently seen being transported by motorbike on National Road 7 that connects the towns of Stung Treng and Kratie. Vast areas of land either side of the road were issued as economic land concessions. Image by Andy Ball / Mongabay.

ដូចគ្នានឹងពលរដ្ឋរាប់ពាន់គ្រួសារដែលត្រូវបានបណ្តេញចេញដើម្បីធ្វើផ្លូវចម្ការ។ខណៈមានអ្នករងការបណ្តេញចេញជាច្រើនបានរកការងារធ្វើជាបណ្តោះអាសន្ននៅលើដីចម្ការនោះ ប៉ុន្តែគ្មានសំណងសម្រាប់កសិដ្ឋានលក្ខណៈគ្រួសារដែលបានបាត់បង់នោះទេ។បន្ទាប់មកនៅពេលដែលអាជីវកម្មស្ករសរបស់កម្ពុជាបានជាប់គាំងនៅក្នុងអ្វីដែលគេហៅថា ជារឿងអាស្រូវស្ករលោហិត ដែលជាយុទ្ធនាការតស៊ូមតិ កំណត់គោលដៅដោយអ្នកទិញនៅអឺរ៉ុប និងអ្នកផ្តល់ហិរញ្ញប្បទានអូស្ត្រាលីអំពីស្ករសកម្ពុជា ដោយសារតែការរំលោភសិទ្ធិដែលមានទំនាក់ទំនងជាមួយឧកញ៉ា ដូចជាលោក លី យ៉ុងផាត់ រោងចក្រចម្រាញ់ស្ករសបានស្ងប់ស្ងាត់ដោយបន្សល់ទុកនូវអតីតអ្នកស្រុកគ្មានដីធ្លី និងគ្មានការងារធ្វើ។

នៅខែធ្នូឆ្នាំ២០២២ ភ្លើងបានឆាបឆេះ

តទៅទំព័រទី១៣



តមកពីទំព័រទី ១២

## ការអំពាវនាវកើនឡើង ដើម្បីយកដី...

ព្រៃមួយកន្លែងក្នុងដីសម្បទានសេដ្ឋកិច្ច Great Field របស់ចិនទំហំ ៩.០៥៩ ហិកតា ក្នុងខេត្តកំពង់ស្ពឺ។ រូបភាពដោយ Andy Ball / Mongabay ។

នេះគ្រាន់តែជាឧទាហរណ៍មួយនៃការបរាជ័យផ្នែកសង្គម បរិស្ថាន និងសេដ្ឋកិច្ចដែលមានរាប់មិនអស់នៃប្រព័ន្ធ ELCរបស់កម្ពុជា ដែលបានបញ្ចប់នៅក្នុងខែឧសភា ឆ្នាំ ២០១២ នៅពេលដែលរដ្ឋាភិបាលបានចេញដីកាហាមឃាត់ការចេញដីសម្បទានសេដ្ឋកិច្ចថ្មី។ ទោះបីជាយ៉ាងណាក៏ដោយ សូម្បីតែសព្វថ្ងៃនេះ សម្បទានិកនៅតែគ្រប់គ្រងផ្ទៃដីប្រមាណ ២.២៥ លាន ហិចតា នៃប្រទេសកម្ពុជា ប្រហែល ១៤% នៃផ្ទៃប្រទេស ឬមានទំហំប៉ុនរដ្ឋ New Jersey តាម រយៈ ELCs 313 នេះបើយោងតាមទិន្នន័យកត់ត្រាដោយអង្គការ លីកាដូ។

បញ្ហាជាច្រើនដែលកើតឡើងដោយប្រព័ន្ធ ELC បានជំរុញឱ្យតួអង្គជាច្រើនមកពីវិស័យឯកជន និងសង្គមស៊ីវិលធ្វើការតស៊ូមតិដើម្បីកំណែទម្រង់ដែលនឹងនាំមកនូវផលប្រយោជន៍រួមកាន់តែច្រើន ទោះបីជាវានៅមិនទាន់ច្បាស់ថាតើ ELC ប៉ុន្មាននៅតែដំណើរការនៅឡើយក៏ដោយ។

ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ ឈើត្រូវបានគេឃើញដឹកតាមម៉ូតូតាមផ្លូវជាតិលេខ៧ ដែលតភ្ជាប់ក្រុងស្ទឹងត្រែងនិងខេត្តក្រចេះ។ ផ្ទៃដីធំទូលាយទាំងសងខាងផ្លូវត្រូវបានចេញជាដីសម្បទានសេដ្ឋកិច្ច។ រូបភាពដោយ Andy Ball / Mongabay

ប្រវត្តិនៃការបរាជ័យដ៍ហូរឈាមមកដល់ពេលបច្ចុប្បន្ន

ស្ទើរតែគ្រប់ការវាស់វែង ប្រព័ន្ធ ELC បានបរាជ័យក្នុងការនាំមកនូវភាពរុងរឿងតាមការសន្យា ផ្ទុយទៅវិញ វានាំទៅរកការបំផ្លិចបំផ្លាញអេកូឡូស៊ីយ៉ាងទូលំទូលាយ ខណៈដែលព្រៃឈើរបស់ប្រទេសកម្ពុជាត្រូវបានកាប់ឆ្ការក្នុងអត្រាចារក្នុងកំណត់ត្រាធ្វើផ្លូវសម្រាប់ចម្ការកសិកម្ម ដែលភាគច្រើនមិនដែលទទួលបានផលឡើយ។ ចាប់តាំងពីឆ្នាំ ១៩៩៨ មក ផ្ទៃដីជាមធ្យម ១០៥០០០ ហិកតា ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ ELC ជារៀងរាល់ឆ្នាំ ដែលរួមចំណែកដោយផ្ទាល់ប្រមាណ ៤០% នៃការកាប់បំផ្លាញព្រៃឈើនៅកម្ពុជា។

លោក អៀង វុទ្ធី នាយកអង្គការសមធម៌កម្ពុជាមានប្រសាសន៍ថា "វានាំឲ្យមានការកាប់បំផ្លាញព្រៃឈើរបស់រដ្ឋយ៉ាងច្រើន ការបណ្តេញចេញ និងការរំលោភសិទ្ធិមនុស្សនៅទូទាំងសហគមន៍ ខណៈដែលបុគ្គលឯកជនទទួលបានផលប្រយោជន៍ពីការកាប់ឈើលើដីរដ្ឋ"។

ការវិភាគដោយអង្គការ ឃ្លាំមើលព្រៃឈើសកល (Global Forest Watch) បង្ហាញថា ព្រៃឈើជាង ៧៧៣០០០ ហិកតា ត្រូវបានបាត់បង់នៅទូទាំងផ្ទៃដី ២.២៥ លានហិកតានៃ ELCs រវាងឆ្នាំ ២០០១ និង ២០២២។ ដោយប្រើទិន្នន័យ ELC របស់លីកាដូ Mongabay បានរកឃើញថា ELCs ចំនួន ១០៤ ត្រួតគ្នា ឬត្រូវបានចេញពីចំណុចកណ្តាលបេះដូងនៃតំបន់ការពារចំនួន ២៣ នៅទូទាំងប្រទេសកម្ពុជា។ ប្រការនេះបានធ្វើឱ្យមានការលួចកាប់ឈើយ៉ាងសន្ធោសន្ធៅ ខណៈអ្នកសម្បទានបានកាប់បំផ្លាញព្រៃឈើក្នុងតំបន់ការពារ ដោយអះអាងថាវាជាព្រៃធម្មជាតិពីក្នុងដីសម្បទានសេដ្ឋកិច្ចរបស់ពួកគេ។ ប្រហែលជាការប្រាប់បន្ថែមទៀត ពីរបៀបនៃការគូសព្រំដែនតំបន់ការពារនៅទូទាំងប្រទេសកម្ពុជាក្នុងឆ្នាំនេះបានដកសម្បទានដីសេដ្ឋកិច្ចពីដីការពារពីមុន។

ការបែងចែក ELCs ច្រើនតែកើតមានពាសពេញតំបន់ព្រៃឈើក្រាស់ៗបំផុតរបស់ប្រទេស កម្ពុជា ដោយអ្នកសម្បទានចង់ទាញយកឈើមានតម្លៃ។ សម្បទានដីសេដ្ឋកិច្ចជាច្រើនជាន់គ្នាជាមួយតំបន់

តទៅទំព័រទី១៤

## Calls grow to repurpose land squandered in Cambodia's concession policy

From Page 12

The range of issues brought about by the ELC system has prompted a range of actors from the private sector and civil society to advocate for reforms that would bring about more shared benefits, although it remains unclear how many ELCs are still operational.

**A history of failure bleeding into the present**

ក្រុមតស៊ូមតិដែលធ្វើការជាមួយសហគមន៍ទាំងនេះ ចង់បានទិន្នន័យបន្ថែមទៀត ជាពិសេសពីប្រទេសចិននេះបើតាមសំដីរបស់លោក ម៉ក់ ប៊ុនធឿន បានបន្ថែមក្នុងកិច្ចសម្ភាសន៍ Zoom កាលពីចុងខែមករា។"ខ្ញុំស្នើឱ្យរដ្ឋាភិបាលនៃទន្លេមេគង្គត្រូវធ្វើការរួមគ្នា សហការដើម្បីធានាថាសហគមន៍ខាងក្រោមនឹងមិនរងទុក្ខ˝៕

តមកពីទំព័រទី ១៧

## HRW ជំរុញឱ្យចលនាខ្មែរដើម្បី...

ដែលស្នេហាប្រជាធិបតេយ្យ និងស្នេហាយុត្តិធម៌ បានមកជួបជុំគ្នានៅទីក្រុងឡុងប៊ិច លើទឹកដីសហរដ្ឋអាមេរិក ដើម្បីអបអរសាទរពិធីសម្ពោធ «ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ» ដែលនឹងត្រូវដឹកនាំដោយអតីតអនុប្រធានគណបក្សសង្គ្រោះជាតិ អ្នកស្រី មូរ សុខហួរ។

ជុំវិញបញ្ហានេះ អតីតអនុប្រធានគណបក្សសង្គ្រោះជាតិ អ្នកស្រី មូរ សុខហួរ បានលើកឡើងថា គោលបំណងនៃការបង្កើតចលនាខ្មែរដើម្បីប្រជាធិបតេយ្យនៅពេលនេះគឺដើម្បីស្វែងរកការរួបរួមចលនាខ្មែរគ្រប់និន្នាការនៅលើពិភពលោក ឆ្ពោះទៅរកការសង្គ្រោះប្រជាធិបតេយ្យនៅកម្ពុជាឱ្យចេញផុតពីការគ្រប់គ្រងតាមបែបគ្រួសារនិយមរបស់គណបក្សប្រជាជនកម្ពុជាសព្វថ្ងៃនេះ។

អ្នកស្រី មូរ សុខហួរ អះអាងថា ចលនាខ្មែរដើម្បីប្រជាធិបតេយ្យមិនមែនជាចលនានយោបាយនោះទេ ប៉ុន្តែជាចលនាអង្គការក្រៅរដ្ឋាភិបាលមួយដែលមានគោលដៅស្វែងរកការសហការជាមួយបុគ្គល និងស្ថាប័នផ្សេងៗ ដើម្បីរួបរួមកម្លាំងគ្នាជួយប្រទេសកម្ពុជាឱ្យងាកទៅរកការអនុវត្តតាមគន្លងប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស បើកលំហសេរីភាពរបស់ពលរដ្ឋឱ្យរស់នៅក្នុងភាពថ្លៃថ្នូរក្នុងនាមជាម្ចាស់ប្រទេសដែលទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ។ អ្នកស្រីបន្តថា ចលនានេះមិនមែនដើម្បីផ្តួលរំលំរដ្ឋាភិបាលកម្ពុជានោះទេ។

ចំណែកអតីតមេដឹកនាំបក្សប្រឆាំង លោក សម រង្ស៊ី បានលើកឡើងកាលពីពេលថ្មីៗនេះថា ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ គឺជាក្តីសង្ឃឹមរបស់ពលរដ្ឋខ្មែរគ្រប់និន្នាការនយោបាយទាំងអស់ក្នុងការចូលរួមកសាងកម្លាំងដើម្បីសង្គ្រោះប្រទេសកម្ពុជាចេញពីកណ្តាប់ដៃត្រកូលហ៊ុន ដែលកំពុងរងនូវការគាបសង្កត់ជិះជាន់សព្វថ្ងៃនេះ។

លោក សម រង្ស៊ី អំពាវនាវឱ្យពលរដ្ឋខ្មែរអ្នកស្នេហាជាតិ អ្នកស្រឡាញ់ប្រជាធិបតេយ្យ ចូលរួមជាមួយចលនាខ្មែរដើម្បីប្រជាធិបតេយ្យ ដើម្បីផ្លាស់ប្តូរការដឹកនាំតាមបែបគ្រួសារនិយមនៅកម្ពុជា ដែលកំពុងគ្រប់គ្រងអំណាចដោយពូជពង្សវង្សត្រកូលគ្រួសារមេដឹកនាំគណបក្សប្រជាជនកម្ពុជាលោក ហ៊ុន សែន សព្វថ្ងៃនេះ៕



តមកពីទំព័រទី ១៨

## សង្គ្រាមនៅអ៊ីស្រ្តាអែល និងហាម៉ាស់

អារ៉ាប់ មិនចង់ឃើញក្រុមហាម៉ាស់ត្រឡប់មកកាន់អំណាចវិញទេ ចំណែកប្រទេសអ៊ីរ៉ង់ នឹងប្រទេសអារ៉ាប់ផ្តាច់ការ រាប់ទាំងក្រុមហាម៉ាស់ផង បែរចង់បានឲ្យក្រុមតឹងតែងស្អប់ជនជាតិជ្វីវ មកកាន់អំណាចទៅវិញ ក៏បុន្តែសហគមន៍អន្តរជាតិ មានសហរដ្ឋអាមេរិកជាដើម ដាក់សម្ពាធធ្ងន់ធ្ងរ ចង់ឲ្យមានសន្តិភាពក្នុងតំបន់ឲ្យបានយូរអង្វែង ហើយប្រគល់គ្នាស្នាទៅឲ្យប៉ាឡេស្ទីនវិញ។

អាចនឹងមានការចរចារសម្រេចឈប់បាញ់គ្នាមួយ នៅមុនចុងបញ្ចប់«រ៉ាម៉ាដង់»នេះ គឺហាម៉ាស់ត្រូវដោះលែងចំណាប់ខ្មាំង១ថ្ងៃបានម្នាក់ ទល់នឹងការដោះលែងឈ្លើយសឹកប៉ាឡេស្ទីនពី២០ទៅ៥០នាក់រាល់ថ្ងៃដូចគ្នាដោយអ៊ីស្រ្តាអែល ការនោះអាចនឹងប្រព្រឹត្តទៅអស់រយៈពេល៣ខែទើបចប់។ធ្វើយ៉ាងនេះអាចជាគារពន្យាពេលឈប់បាញ់គ្នាបានយ៉ាងយូរបន្តិច សម្រាប់ក្រុមសង្គ្រោះជួយការពារពួកជនភៀសខ្លួនប៉ាឡេស្ទីនបាន។

រូបមន្តថ្មីនេះ បើទទួលបានការអនុម័ទ ទំនងជាហាម៉ាស់ដែលមានទំនោរភេរវកម្ម ត្រូវថយខ្លួនចេញពីតំបន់ដោយចុះចាញ់ ទុកឲ្យជនប៉ាឡេស្ទីនមកបន្តរគ្រប់គ្រងគ្នាស្នាវិញ ដែលគំនិតនេះអាចឲ្យអ៊ីស្រ្តាអែលយល់ព្រមបាន៕



តមកពីទំព័រទី ២០

## ការអំពាវនាវកើនឡើង ដើម្បីយកដី...

ត្បូងមានតម្លៃ។ រូបភាពដោយ Gerald Flynn / Mongabay

ជៀសវាង "ការបរាជ័យមួយទៀត˝

រាល់ដំណោះស្រាយ ត្រូវចាប់ផ្តើមពីសកម្មភាពពីលើចុះក្រោមពីរដ្ឋាភិបាលដើម្បីបណ្តេញ សម្បទានិកពីដីសម្បទានសេដ្ឋកិច្ចដែលខ្លួនមិនប្រើប្រាស់។ លោក Jean-Christophe Diepart អ្នកជំនាញភូមិសាស្រ្តកសិកម្មដែលមានបទពិសោធន៍ជាង ២០ ឆ្នាំ នៅកម្ពុជា បាននិយាយថា ទោះជាយ៉ាងណាក៏ដោយ តួនាទីរបស់សហគមន៍មូលដ្ឋាននឹងជាចំណុចស្នូលនៃភាពជោគជ័យនៃកំណែទម្រង់ប្រព័ន្ធ ELC ហើយនឹងត្រូវការពិចារណាយ៉ាងប្រុងប្រយ័ត្ន ដើម្បីជៀសវាងការធ្លាក់ចូលទៅក្នុងប្រព័ន្ធចាស់។

លោក Diepart បាននិយាយថា "ថាតើELCsពិតជាបានផ្តល់ឱ្យតាមការសន្យារបស់ពួកគេ ដើម្បីនាំមកនូវការអភិវឌ្ឍន៍សេដ្ឋកិច្ច សម្រាប់ខ្ញុំវាពិតជាគ្មានទេ" ។ "ការផ្លាស់ទីលំនៅរបស់ប្រជាជនមានទំហំធំធេង មិនតាមបរិមាណសមស្រប ទេ ប៉ុន្តែនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ ហើយវាបានធ្វើឱ្យមានរលកនៃការធ្វើចំណាកស្រុកជាច្រើនដែលឃើញប្រជាជន ត្រូវបានផ្លាស់ប្តូរចូលទៅក្នុងព្រៃ"។

Diepart ជាអ្នកនិពន្ធឯកសារស្តីពីអសន្តិសុខដីធ្លីក្នុងប្រទេសកម្ពុជាបានចង្អុលបង្ហាញពីកង្វះយន្តការបណ្តឹងតវ៉ា រួមមួយយល់ព្រមដោយសេរីការយល់ព្រមជាមុននិងផ្តល់ព័ត៌មាននិងគោលនយោបាយដោះស្រាយវិវាទដីធ្លីនៅទូទាំងប្រព័ន្ធ ELC ។

កាលពីខែឧសភា ឆ្នាំ ២០២៣ ប្រជាពលរដ្ឋនៅឧទ្យានជាតិបុទុមសាគរ ក្នុងខេត្តកោះកុងបានប្រាប់ម៉ុងហ្គាបេ អំពីការលំបាកទាក់ទងនឹងការរស់នៅកន្លែងផ្លាស់ប្តូរទីលំនៅបន្ទាប់ពីភូមិរបស់ពួកគេត្រូវបានប្រគល់ទៅឱ្យអ្នកសម្បទានដែលមានទំនាក់ទំនងនយោបាយ។ រូបភាពដោយ Gerald Flynn / Mongabay

លោក Diepart បាននិយាយថា សម្បទានិកនីមួយៗមានសេរីភាពក្នុងការដោះស្រាយជាមួយសហគមន៍ ដែលពួកគេមើលឃើញថាសមរម្យ។ ជារឿយៗនេះបណ្តាលឱ្យមានឧបាយកលប្រើដៃធ្ងន់ៗ និងបង្កើតជម្លោះក្លាយទៅជាហិង្សានៅពេលដែលសហគមន៍មានអារម្មណ៍ថាដីរបស់ពួកគេកំពុងត្រូវបានគេលួច។

លោកបានមានប្រសាសន៍ថា នេះក៏បានរួមចំណែកដល់ការបរាជ័យចុងក្រោយនៃ ELCs នៅពេលដែលពួកគេឈរ ដោយសារអ្នកសម្បទានកាន់តែច្រើនបានបដិសេធមិនបង់ពន្ធនៅពេលដែលពួកគេមានអារម្មណ៍ថារដ្ឋាភិបាល មិនបានគាំទ្រពួកគេក្នុងការដោះស្រាយជាមួយសហគមន៍ដែលរងទុក្ខ ឬត្រូវបណ្តេញចេញពីអាជីវកម្មចំណាយលើការដោះស្រាយវិវាទដីធ្លី។

"ក្នុងចំណោមថវិកាចំនួន ២.២ ពាន់លានដុល្លារឬច្រើនជាងនេះ[ប្រាក់ចំណូលដែលបង្កើតសម្រាប់រដ្ឋ] គឺពិតជាមិនច្រើនទេ ជាពិសេសនៅពេលអ្នកគិតគូពីផលប៉ះពាល់ដែល ELCs មាន។ វាពិតជាមិនមានតុល្យភាពជាមួយនឹងផលប៉ះពាល់អវិជ្ជមាននោះទេ˝។ លោកបានមានប្រសាសន៍ថា ប្រព័ន្ធ ELC កំពុងធ្លាក់ចុះទៅក្នុងភាពមិនពាក់ព័ន្ធខាងសេដ្ឋកិច្ច។ "មានការទទួលស្គាល់ថារឿងទាំងមូលមិនដំណើរការត្រឹមត្រូវទេ ប៉ុន្តែអ្នកវិនិយោគក៏មានការស្ទាក់ស្ទើរក្នុងការវិនិយោគលើដីធ្លីដែរ ព្រោះពួកគេដឹងថាវាជាតំបន់ដែលពិបាកចិត្ត និងមានបញ្ហាខ្លាំងណាស់˝។

លោក Diepart បាននិយាយថា បញ្ហាទាំងនេះនឹងនៅតែមាននៅក្នុងកំណែទម្រង់ណាមួយចំពោះប្រព័ន្ធ ELC ដែលផ្លាស់ប្តូរកម្រិតនៃការទទួលបានដីធ្លីសម្រាប់សហគមន៍។ លោក Diepart បាននិយាយថា សិទ្ធិ និងសន្តិសុខដីធ្លីរបស់ប្រជាជនកម្ពុជាត្រូវតែជាស្នូលនៃគោលនយោបាយសក្តានុពលណាមួយទាក់ទងនឹង ELCs អសកម្ម។

លោកបានមានប្រសាសន៍ថា "រាល់ការប៉ុនប៉ងដាំដើមឈើឡើងវិញ ឬធ្វើអ្វីមួយ នៅក្នុង ELCs ដែលអសកម្មទាំងនេះ ចាំបាច់ត្រូវគិតគូរ ហើយធ្វើយ៉ាងយកចិត្តទុកដាក់បំផុតចំពោះបញ្ហានៃការធ្វើចំណាកស្រុក˝។ "នេះជាបញ្ហានៃការបែងចែកឲ្យប្រជាជនធ្វើកសិកម្មឡើងវិញនៅក្នុង ប្រទេស។ បើអ្នកមិនយករឿងនេះមកគិតគូរទេ ខ្ញុំចង់និយាយថា វាជាការបរាជ័យផ្សេងទៀត˝

រូបភាពបដា៖ កាលពីខែកុម្ភៈ ឆ្នាំ២០២៣ ក្រុមហ៊ុនដែលមានទំនាក់ទំនងនយោបាយ គឺលោក សាល សុភា ភានិច ត្រូវបានគេមើលឃើញថា កំពុងឈូសឆាយព្រៃឈើធម្មជាតិនៅក្នុងដីសម្បទានរបស់ខ្លួនក្នុងខេត្តស្ទឹងត្រែង។ រូបភាពដោយ Andy Ball / Mongabay

### NOTICE OF PUBLIC MEETING

The next meeting of the Northern Middlesex Metropolitan Planning Organization (MPO) will be held on April 24, 2024 at 2:00 PM. NMMPO meetings are held virtually via Zoom and in person at 672 Suffolk Street, Suite 100, Lowell, MA. The full agenda and information about the meeting will be posted at www.nmcog.org/calendar. The NMMPO provides reasonable accommodations and/or language assistance free of charge upon request (including but not limited to interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Lesley Shahbazian at (978) 454-8021 or at lshahbazian@nmcog.org. Requests should be made for services requiring accommodations.

### សេចក្តីជូនដំណឹងស្តីពីកិច្ចប្រជុំជាសាធារណៈ

កិច្ចប្រជុំបន្ទាប់នៃអង្គការផែនការមេត្រូប៉ូលីតខាងជើង ហៅកាត់ថា (MPO) នឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០២៤ វេលាម៉ោង ២:០០រសៀល។កិច្ចប្រជុំ NMMPO ធ្វើឡើងតាមវេទិកា Zoom និងដោយផ្ទាល់នៅទីតាំងតាមអសយដ្ឋាន 672 Suffolk Street, Suite 100, ក្រុងឡូវែល រដ្ឋម៉ាសាឈូសេត ។ របៀបវារៈពេញលេញ និងព័ត៌មានអំពីកិច្ចប្រជុំនេះ នឹងត្រូវបានបង្ហោះនៅលើគេហទំព័រ www.nmcog.org/calendar ។ NMMPO ផ្តល់នូវការស្នាក់នៅសមរម្យ និង/ឬជំនួយភាសាដោយមិនគិតថ្លៃតាមការស្នើសុំ (រួមទាំងប៉ុន្តែមិនកំណត់ចំពោះអ្នកបកប្រែភាសាសញ្ញាអាមេរិក និងភាសាផ្សេងក្រៅពីភាសាអង់គ្លេស មានអក្សររត់លើអេក្រង់វីដេអូ ឧបករណ៍ជំនួយការស្តាប់ និងទម្រង់ សម្ភារៈជំនួស) ។ សម្រាប់ជំនួយ សូមទាក់ទង Lesley Shahbazian តាមលេខទូរស័ព្ទ (978) 454-8021 ឬតាមអ៊ីម៉ែល lshahbazian@nmcog.org ។ការស្នើសុំសម្រាប់កន្លែងស្នាក់នៅគួរតែត្រូវបានធ្វើឡើងផងដែរ៕

# អភិបាល Healey បានប្រកាសពីគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយការផ្លាស់ប្តូរកែលម្អនៅទីក្រុងឡូវែល

**Draper សម្របសម្រួលការអភិវឌ្ឍន៍ដែលនាំមកនូវការងាររាប់រយសម្រាប់តំបន់ឡូវែល**

ឡូវែល៖ អភិបាលរដ្ឋ លោកស្រី Maura T. Healey បានប្រកាសពីព្រឹត្តិការណ៍ដ៏សំខាន់មួយក្នុងគម្រោងផ្លាស់ប្តូរកែលម្អដែលនឹងនាំមកនូវលំនៅដ្ឋានថ្មីការអភិវឌ្ឍន៍សេដ្ឋកិច្ច ការងារបច្ចេកវិទ្យា និងការអភិវឌ្ឍកម្លាំងពលកម្មសម្រាប់ទីក្រុងឡូវែល។ មន្ទីរពិសោធន៍ Draper ជាស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញ នឹងក្លាយជាអ្នកសម្របសម្រួលនៅក្នុងច្រករបៀងបណ្តាញនវានុវត្តន៍ក្រុងឡូវែល (Lowell Innovation Network Corridor) ជាដៃគូសាធារណៈ និងឯកជនធ្វើឲ្យមានផ្លាស់ប្តូរកែលម្អ ដឹកនាំអនុវត្តដោយសាកលវិទ្យាល័យម៉ាសាឈូសេតឡូវែល (UML) UMass អាជ្ញាធរមើលការខុសត្រូវលើអគារ (UMBA) និងក្រុងឡូវែល មានការគាំទ្រពេញទំហឹងពីរដ្ឋបាល Healey-Driscoll ។

ការប្រកាសនេះត្រូវបានធ្វើឡើងនៅ UMass Lowell ជាមួយអភិបាលលោកស្រី Healey អភិបាល Driscoll តំណាងរាស្ត្រ លោកស្រី Lori Trahan អ្នកគ្រប់គ្រងទីក្រុងឡូវែល លោក Thomas A. Golden, Jr., ប្រធានមហាវិទ្យាល័យម៉ាសាឈូសេតអធិការបតី Marty Meehan UMass Lowell លោកស្រី Julie Chen នាយិកាប្រតិបត្តិ UMBA លោកស្រី Barbara Kroncke និង លោក Jerry Wohletz ប្រធាន និងនាយកប្រតិបត្តិ Draper ។

គម្រោងនេះត្រូវបានគេរំពឹងថានឹងរកចំណូលបានបានជាង ៣.៧ ពាន់លានដុល្លារតាមសកម្មភាពសេដ្ឋកិច្ច និងបង្កើតការងារអចិន្ត្រៃយ៍ចំនួន ២០០០ កន្លែង ក្នុងរយៈពេលមួយទសវត្សរ៍ក្រោយ។ វាក៏នឹងបង្កើតការងារសំណង់ចំនួន ១៣០០ និងមានលទ្ធផលជាលំនៅដ្ឋានថ្មីជិត ៥០០ បន្ទប់នៅក្រុងឡូវែល រួមជាមួយនឹងចំណូលពន្ធអចលនទ្រព្យប្រចាំឆ្នាំថ្មីជាច្រើនលានដុល្លារថែមទៀតសម្រាប់ទីក្រុង។

អភិបាល Healey មានប្រសាសន៍ថា "នេះមិនមែនជាគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកនដោយការផ្លាស់ ប្តូរកែលម្អសម្រាប់តែទីក្រុងឡូវែលនោះទេ វាក៏សម្រាប់តំបន់ និងរដ្ឋម៉ាសាឈូសេតផងដែរ។ មជ្ឈមណ្ឌល នវានុវត្តន៍ដ៏អស្ចារ្យបន្ទាប់នឹងមានវត្តមាននៅទីក្រុងឡូវែល" ។ "LINC នឹងបង្កើតបានថវិការាប់ពាន់លាននៅក្នុងសកម្មភាពសេដ្ឋកិច្ច បង្កើតការងាររាប់ពាន់ និងលំនៅដ្ឋានរាប់រយបន្ទប់ ដែលជាតម្រូវការបន្ទាន់ និងពង្រីកការបណ្តុះបណ្តាលកម្លាំងការងារសម្រាប់សិស្សរបស់យើង។ យើងអរគុណចំពោះភាពជាដៃគូរបស់សមាជិកសភា Trahan ទីក្រុងឡូវែល និងសាកលវិទ្យាល័យនៃរដ្ឋម៉ាសាឈូ



Lt. Governor Kim Driscoll, UML Chancellor Julie Chen, Governor Maura Healey, Congresswoman Lori Trahan, District #3

សេត ដែលធ្វើឱ្យគម្រោងផ្លាស់ប្តូរកែលម្អនេះអាចធ្វើទៅបាន។ យើងស្វាគមន៍ចំពោះការបន្ថែមរបស់ Draper ទៅក្នុងគម្រោង LINC ហើយសង្ឃឹមថាអ្នកបង្កើតថ្មីផ្សេងទៀតនឹងមើលឃើញឱកាសមិនគួរឱ្យជឿនៅទីនេះ នៅទីក្រុងឡូវែល។

អភិបាលរង Kim Driscoll មានប្រសាសន៍ថា "LINC នឹងជះឥទ្ធិពលយ៉ាងសំខាន់ទៅលើការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចរបស់ទីក្រុងឡូវែល" ។ "វានឹងបង្កើតលំនៅឋានបន្ថែមទៀត ដើម្បីឱ្យសិស្ស និង កម្មករអាចមានលទ្ធភាពរស់នៅទីនេះ នាំយកការងារថ្មីៗមកតំបន់នេះ និងធ្វើការកែលម្អយ៉ាងសំខាន់ទៅកាន់បរិវេណសាលា UMass Lowell គាំទ្រដល់ការងារប្រកបដោយភាពច្នៃ ប្រឌិត និងទំនើបបំផុតដែលពួកគេកំពុងធ្វើ។ ការប្តេជ្ញាចិត្តចំពោះភាពជោគជ័យរបស់

តទៅទំព័រទី២៧

# Governor Healey Annouced Transformative Economic Development Project in Lowell

*Draper to anchor the development, bringing hundreds of jobs to Lowell region*

LOWELL – Governor Maura T. Healey announced a major milestone in a transformative project that will bring new housing, economic development, technology jobs and workforce development to downtown Lowell. The research non-profit, Draper Laboratory (Draper) will become an anchor tenant in the Lowell Innovation Network Corridor (LINC), a transformative public-private partnership made possible by the leadership of the University of Massachusetts Lowell (UML), the UMass Building Authority (UMBA) and the City of Lowell, with significant support from the Healey-Driscoll administration.

The announcement was made at UMass Lowell with Governor Healey, Lieutenant Governor Driscoll, Congresswoman Lori Trahan, Lowell City Manager Thomas A. Golden, Jr., University of Massachusetts President Marty Meehan, UMass Lowell Chancellor Julie Chen, UMBA Executive Director Barbara Kroncke, and Draper President and CEO Jerry Wohletz.

The project is expected to generate over $3.7 billion in economic activity and create 2,000 permanent jobs over the next decade. It will also create 1,300 construction jobs and result in nearly 500 units of new housing in Lowell, along with several million dollars in new annual property tax revenues to the City.

"This is nothing short of a transformational economic development project for Lowell, the region, and Massachusetts. The next great innovation hub is going to be right here in Lowell," said Governor Healey. "The LINC will generate billions in economic activity, create thousands of jobs and hundreds of units of urgently needed housing, and expand workforce training for our students. We're grateful for the partnership of Congresswoman Trahan, the City of Lowell, and the University of Massachusetts to make this transformative project possible. We welcome the addition of Draper to the LINC Project and hope that other innovators will see the incredible opportunities here in Lowell."

"The LINC will have significant impacts on Lowell's economic competitiveness," said Lieutenant Governor Kim Driscoll. "It will create more housing so that students and workers can afford to live here, bring new jobs to the area, and make critical improvements to the UMass Lowell campus to support the cutting-edge, innovative work they are doing. This administration is deeply committed to Lowell's success and we are proud to be working on this project with so many dedicated partners."

"There has never been a better time to call Lowell home. We've secured unprecedented federal, state, and private sector funding to position the Mill City for a multi-billion dollar economic and jobs boom over the next ten years," said Congresswoman Lori Trahan. "Much of that will be anchored in the Lowell Innovation Network Corridor, which will be home to cutting edge businesses like Draper, leading R&D initiatives, and hundreds of housing units. I'm proud to have worked alongside the City of Lowell, UMass Lowell, the Healey-Driscoll Administration, and industry to create a public private partnership that will provide investments in the LINC and downtown so we can continue driving Lowell's tremendous revitalization."

"We are thrilled to support this transformational project in an important Gateway City," said Secretary of Economic Development Yvonne Hao. "The Lowell Innovation Network Corridor will ensure that we are creating big wins for life sciences, climatetech, and other innovative industries not just in Greater Boston, but across the state."

A cornerstone of the LINC will be a new research building on UMass Lowell's East Campus that will be the future home of Draper's microelectronics division. This will result in hundreds of new jobs being located in Lowell, and the building will serve as an anchor to Massachusetts' next regional innovation hub.

Please see /26



## តមកពីទំព័រទី ២៦ អភិបាល Healey បានប្រកាសពី...

ទីក្រុងឡូវែល យើងមានមោទនភាពដែលបានធ្វើការលើគម្រោងនេះជាមួយដៃគូដែលខិតខំប្រឹងប្រែងជាច្រើន" ។

សមាជិកសភាលោកស្រី Lori Trahan បានមានប្រសាសន៍ថា "គ្មានពេលវេលាណាដែលល្អប្រសើរជាងផ្ទះរបស់យើងនៅក្រុងឡូវែលនោះទេ។ យើងទទួលបានមូលនិធិពីសហព័ន្ធរដ្ឋ និងឯកជនដែលមិនធ្លាប់មានពីមុនមកដើម្បីដាក់ទីតាំង Mill City សម្រាប់វិស័យសេដ្ឋកិច្ច និងការងារដែលមានតម្លៃរាប់ពាន់លានដុល្លារក្នុងរយៈពេលដប់ឆ្នាំទៅមុខ" ។ "ភាគច្រើន នឹងត្រូវបានអនុវត្តនៅតាមច្រករបៀងបណ្តាញនវានុវត្តន៍ក្រុងឡូវែល ដែលនឹងក្លាយជាផ្ទះសម្រាប់អាជីវកម្មឈានមុខគេ ដូចជា Draper គំនិតផ្តួចផ្តើម R&D ឈានមុខគេ និងផ្ទះរាប់រយខ្នង។ ខ្ញុំពិតជាមានមោទនភាពដែលបានធ្វើការរួមគ្នាជាមួយទីក្រុងឡូវែល UMass Lowell រដ្ឋបាល Healey-Driscoll និងឧស្សាហកម្មនានា ដើម្បីបង្កើតភាពជាដៃគូរវាងឯកជន និងសាធារណៈដែលនឹងផ្តល់ការវិនិយោគនៅក្នុង LINC និងទីប្រជុំជន ដូច្នេះយើងអាចបន្តជំរុញការរស់ឡើងវិញដ៏អស្ចារ្យរបស់ក្រុងឡូវែល ។

លោកស្រី Yvonne Hao លេខាធិការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចបានមានប្រសាសន៍ថា "យើងពិតជារំភើបចិត្ត គាំទ្រគម្រោងផ្លាស់ប្តូរកែលម្អនេះ នៅក្នុងទីក្រុងច្រកចេញចូលនេះ" ។ "ច្រករបៀងបណ្តាញនវានុវត្តន៍ទីក្រុងឡូវែលនឹងធានាថា យើងកំពុងបង្កើតការយកឈ្នះដ៏ធំសម្រាប់វិទ្យាសាស្ត្រជីវិត បច្ចេកវិទ្យាអាកាសធាតុ និងឧស្សាហកម្មច្នៃប្រឌិតផ្សេងទៀត មិនត្រឹមតែនៅទីក្រុងបូស្តុនប៉ុណ្ណោះទេ ប៉ុន្តែនៅ ទូទាំងរដ្ឋទាំងមូល" ។

មូលដ្ឋានគ្រឹះនៃ LINC នឹងក្លាយជាអគារស្រាវជ្រាវថ្មីមួយនៅលើបរិវេណខាងកើត UMass Lowell ដែលនឹងក្លាយជាផ្ទះនាពេលអនាគតនៃផ្នែកមីក្រូអេឡិចត្រូនិចរបស់ Draper ។ នេះនឹងបណ្តាលឱ្យមានការងារថ្មីរាប់រយដែលមានទីតាំងនៅទីក្រុងឡូវែល អគារនេះនឹងបម្រើជាគ្រឹះសម្រាប់មជ្ឈមណ្ឌលច្នៃប្រឌិតក្នុងតំបន់បន្ទាប់របស់រដ្ឋម៉ាសាឈូសេត ។

រដ្ឋបាល Healey-Driscoll បានប្តេជ្ញាធ្វើការជាមួយទីក្រុងឡូវែល និងសាកលវិទ្យាល័យម៉ាសាឈូសេត ដើម្បីគាំទ្រគម្រោងនេះជាមួយនឹងថវិការដ្ឋដែលមាន។ លក្ខខណ្ឌចុងក្រោយ កំពុងត្រូវបានរៀបចំ។

Healey បានសរសើរការដឹកនាំរបស់ប្រធាន UMass លោក Marty Meehan អធិការបតី UMass Lowell លោកស្រី Julie Chen នាយិកាប្រតិបត្តិ UMBA លោកស្រី Barbara Kroncke ប្រធាន Draper និង CEO Jerry M. Wohletz និងអ្នកគ្រប់គ្រងទីក្រុងឡូវែល លោក Thomas A. Golden, Jr. ដោយនិយាយថា លោកស្រីរំពឹងថា នឹងមានអង្គការបន្ថែមទៀត ប្រកាសពីការពង្រីកចូលទៅក្នុងសាកលវិទ្យាល័យ និង ទីក្រុងតាមរយៈគម្រោង LINC ក្នុងប៉ុន្មានខែខាងមុខនេះ។

Marty Meehan ប្រធានសាកលវិទ្យាល័យម៉ាសាឈូសេត អតីតនិស្សិត និងជាអតីតអធិការបតីនៃ UMass Lowell ដែលបានចាប់ផ្តើមដំណើរការនៃការទទួលបានអចលនទ្រព្យទាក់ទងនឹងការអភិវឌ្ឍ LINC ខណៈពេលដែលជាអធិការបតី និងបានបន្តចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងនោះបាននិយាយថា "ទម្រាំមានថ្ងៃនេះ "វាត្រូវការការអត់ធ្មត់ ការតស៊ូ និងចក្ខុវិស័យដើម្បីបង្វែរគំនិតផ្តួចផ្តើមបែបនេះពីក្តីស្រមៃឲ្យក្លាយជាការពិត ហើយវាគឺជាអភិបាល Healey ដែលបានផ្តល់នូវភាពជាអ្នកដឹកនាំដ៏ក្លាហានដើម្បីធ្វើឱ្យថ្ងៃនេះកើតឡើង។ ការបញ្ចូលគ្នានៃសហគមន៍ដែលមានការស្វាគមន៍ ដូចជាស្រុកកំណើតរបស់ខ្ញុំ ដែលជាសាកលវិទ្យាល័យសាធារណៈលំដាប់ពិភពលោក និយោជកឈានមុខគេក្នុងឧស្សាហកម្ម ដូចជា Draper គាំទ្រដោយការវិនិយោគរបស់រដ្ឋជាយុទ្ធសាស្ត្រនឹងនាំមកនូវអត្ថប្រយោជន៍សេដ្ឋកិច្ចយ៉ាងសម្បើមដល់ទីក្រុងឡូវែល និងអ្នកស្រុករបស់ខ្លួន"។

Julie Chen អធិការបតីនៃ UMass

តទៅទំព័រទី២៩

## Governor Healey Annouced Transformative Economic Development Project in Lowell

From Page 26

The Healey-Driscoll administration has committed to working with the City of Lowell and the University of Massachusetts to support this project with available state funding. Final terms are under development.

Healey touted the leadership of UMass President Marty Meehan, UMass Lowell Chancellor Julie Chen, UMBA Executive Director Barbara Kroncke, Draper President and CEO Jerry M. Wohletz, and Lowell City Manager Thomas A. Golden, Jr., saying she expected additional organizations would be announcing expansion into university and city facilities through the LINC project in the coming months.

"Today has been a long time coming," said University of Massachusetts President Marty Meehan, an alumnus and former chancellor of UMass Lowell, who started the process of acquiring property related to the LINC development while chancellor and has remained actively engaged in those efforts as president. "It takes patience, perseverance and vision to turn initiatives like this from dream to reality, and it is Governor Healey who has provided the bold leadership to make today happen. The combination of a welcoming community like my hometown, a world-class public university, and an industry-leading employer like Draper – all supported by strategic state investment – will bring enormous economic benefits to the city of Lowell and its residents."

"UMass Lowell has a wide range of top-tier faculty expertise and we partner with organizations across many different industries," said Julie Chen, Chancellor of UMass Lowell. "Thanks to the Healey-Driscoll administration and partners like Draper, UMass Lowell will be able to dramatically scale up research around aerospace, human performance, advanced textiles, robotics, sensors and many other sectors that will bring a diversity of education and job opportunities to Lowell."

"Our expansion to Lowell marks a significant milestone in our mission to drive innovation in Massachusetts and across the U.S.," said Dr. Jerry M. Wohletz, chief executive officer and president at Draper. "We are grateful to Governor Healey, her team, and the University of Massachusetts-Lowell for their partnership. Universities are engines of innovation, with powerful ideas that the world needs, but making those ideas real is no small task. Draper is here to help with



Governor Healey shakes hand with Congresswoman Lori Trahan. Photo via Governor Healey's X (Twitter)

mentorships, prototype testing and development and opportunities for customer collaborations that result in fielded and deployed solutions."

Lowell City Manager Thomas A. Golden, Jr. said the city is thrilled to welcome Draper to Lowell and believes the collaborative work with the university on LINC will bring in more firms who have connections to the university and want to work closely with organizations like Draper.

"LINC will retain and attract professionals to Lowell as well as ramp up economic development entertainment and culture for Lowell residents," Golden said, adding that the city and UMass Lowell are also planning infrastructure improvements as more people live and work in Lowell.

Visit https://www.lowell-inc.com/ to learn more about LINC and the strategic plans to drive economic development in Lowell.

## Challenging The Misguided Proposal To Legitimize Hun Manet's Hereditary Appointment

As members of the Khmer Community, we hereby protest and distance ourselves from the proposal to "legitimize" what the United Nations properly challenged as the "hereditary appointment" of Hun Manet as Prime Minister by his father Hun Sen. We do not accept nor support Mu Sochua's misguided effort along those lines. The strategy of attempting to accommodate with Hun Sen was tried many times over the past years with no success. That failure was epitomized by Hun Sen's rejection of the election results on several occasions in the past, and most recently by his total elimination of the viable political opposition parties in the run-up to the 2023 national elections, accompanied by his initiation of "Mass Criminal Trials" of opposition leaders and other critics of the government.

Our attention and advocacy efforts, and those of the international community through such mechanisms as the Cambodia Universal Periodic Review hearing scheduled before the Human Rights Council on 8 May 2024, need to remain focused on challenging and protesting the Hun Sen/Hun Manet regime's extensive and long-standing human rights and democracy abuses.

Giving the Hun Sen/Hun Manet regime another chance to reject efforts at accommodation in order to retain their power by eliminating meaningful opposition and by rejecting effective change for Cambodia, is a failed strategy that cannot be repeated.

Email: khmunity@savecambodia.org

សហព័ន្ធខ្មែរកម្ពុជាក្រោម

KHMERS KAMPUCHEA-KROM FEDERATION

4315 50th Street NW, Suite 100, PMB 7005, Washington, DC 20016 – https://khmerkrom.org - info@khmerkrom.org - (202) 280-7362

FOR IMMEDIATE PRESS RELEASE

*Khmers Kampuchea-Krom Federation Condemns Arrest and Defrocking of Venerable Thach Chanh Da Ra by Vietnamese Authorities*

**WASHINGTON, D.C., 26 March 2024** — The Khmers Kampuchea-Krom Federation (KKF) expresses grave concern over the recent arrest and defrocking of Venerable Thach Chanh Da Ra, the respected Abbot of Tro Nom Sek temple in Dai Tho hamlet, Long My village, Tam Binh District, Vinh Long province, on March 26, 2024.

Venerable Thach Chanh Da Ra, while returning from conducting a blessing at the Religious Hall in Tong Hung hamlet, was arrested by Vietnamese authorities along with Mr. Kim Khiem. After many hours of disappearance, the online newspaper of the Department of Internal Security of Vinh Long Provincial Police reports that Venerable Thach Chanh Da Ra and Mr. Kim Khiem are being detained under the charge of "abusing democratic freedoms" (Article 331 of the Vietnamese Criminal Code), a charge frequently used against Khmer-Krom activists. On the same day, Mr. Thach Ve Sanal was also arrested under Article 157 for merely assisting in the defense of Tro Nom Sek temple when local gang members attacked the temple on November 22, 2023.

The background leading to this distressing incident dates back to December 3, 2023, when Vietnamese authorities and the Vietnam Buddhist Sangha (VBS) threatened to disavow Venerable Thach Chanh Da Ra as a Buddhist monk. The Tro Nom Sek temple, a Khmer-Krom sanctuary, has been coerced into VBS affiliation despite the community's deliberate decision to maintain autonomy and practice Theravada Buddhism independently. The VBS failed to defrock Venerable Thach Chanh Da Ra due to the resistance of the Khmer-Krom community because he did not violate any Buddhist rules. Ironically, The Vietnamese authorities now arrest him and charge him with a different crime that he has not committed. He merely exercises his right to freely advocate for the right to practice Theravada Buddhism for his indigenous Khmer-Krom community.

We demand the immediate release of Venerable Thach Chanh Da Ra, Mr. Kim Khiem, and Mr. Thach Ve Sanal and the dismissal of all charges against them. Venerable Thach Chan Da Ra should be allowed to be a Buddhist monk and continue leading his temple as the Abbot. The Vietnamese authorities must respect the Khmer-Krom's right to practice their religion freely and without fear of persecution.

We implore the United Nations and international community to condemn the Vietnamese government's suppression of religious freedom, calling upon Vietnam to fulfill its obligations as a member of the Human Rights Council and to demand respect for the autonomy and spiritual practices of the indigenous Khmer-Krom community.

## ប្រធានបទ៖ លិខិតជំទាស់ចំពោះការចង់ឲ្យ ហ៊ុនម៉ាណែតបានភាពស្របច្បាប់ជានាយករដ្ឋមន្ត្រី បន្តពូជ

ក្នុងនាមជាសមាជិកនៃសហគមន៍ខ្មែរ យើងសូមធ្វើការតវ៉ា ដោយមិនយល់ស្របនឹងសំណើសុំ "ធ្វើឱ្យស្របច្បាប់" នូវអ្វីដែលអង្គការសហប្រជាជាតិបានជំទាស់យ៉ាងខ្លាំងពី "ការតែងតាំងតពូជ" លោក ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រីដោយឪពុករបស់គាត់គឺលោក ហ៊ុន សែន។ យើងមិនអាចទទួលយក ឬគាំទ្រដំណើរ របស់អ្នកស្រី មូរ សុខហួរ ដែលគាត់ ខិតខំ តាមខ្សែបន្ទាត់ ដែលយើងយល់ថាជាផ្លូវខុសទាំងស្រុង។ យុទ្ធសាស្ត្រព្យាយាមសម្រុះសម្រួលខ្លួនជាមួយលោក ហ៊ុន សែន ធ្លាប់បានសាកល្បងជាច្រើនដងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដោយ មិនបានជោគជ័យឡើយ។ ការបរាជ័យនោះ បង្ហាញឱ្យឃើញយ៉ាងច្បាស់ គឺដោយសារលោក ហ៊ុន សែន បដិសេធលទ្ធផលបោះឆ្នោតជាច្រើនលើកកន្លងមក ហើយថ្មីៗនេះ គាត់លុបបំបាត់ចោល ទាំងស្រុងតែម្តងនូវគណបក្សនយោបាយណាដែលអាចទទួលបានសម្លេងច្រើនក្នុងការបោះឆ្នោតជាតិឆ្នាំ ២០២៣ ព្រមជាមួយនឹងការផ្តួចផ្តើមគំនិតនៃ "ការកាត់ក្តីឧក្រិដ្ឋកម្ម ជាទ្រង់ទ្រាយធំ" ទៅលើថ្នាក់ដឹកនាំបក្សប្រឆាំង និងអ្នករិះគន់រដ្ឋាភិបាលផ្សេងទៀត។

ការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិរបស់យើង និងសហគមន៍អន្តរជាតិ តាមរយៈយន្តការដូចជា សវនាការពិនិត្យតាមកាលកំណត់ជាសកលរបស់កម្ពុជា ដែលគ្រោងធ្វើ ឡើងនៅចំពោះមុខក្រុមប្រឹក្សាសិទ្ធិមនុស្សនៅថ្ងៃទី ៨ ឧសភា ឆ្នាំ ២០២៤ ចាំបាច់ត្រូវតែបន្ត ផ្តោតទៅលើបញ្ហាប្រឈម និងការតវ៉ាចំពោះរបប ហ៊ុន សែន/ហ៊ុន ម៉ាណែត ដែលយូរអង្វែង ណាស់មកហើយ ប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្ស និងមិនគោរពលទ្ធិប្រជាធិបតេយ្យ។

ការផ្តល់ឱកាសឱ្យរបប ហ៊ុន សែន/ហ៊ុន ម៉ាណែត បដិសេធកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ អន្តរជាតិក្នុងការសម្របសម្រួល ឲ្យរបបនេះរក្សាអំណាចដោយលុបចោលអ្នកប្រឆាំង ដែលមាន ឥទ្ធិពល និងដោយបដិសេធការផ្លាស់ប្តូរប្រកបដោយប្រសិទ្ធភាពសម្រាប់កម្ពុជានោះ គឺជា យុទ្ធសាស្ត្រ បរាជ័យដែលមិនអាចអនុញ្ញាត្តិឲ្យកើតឡើងម្តងទៀតបានឡើយ៕

Email: khmunity@savecambodia.org

ការបង្កើនចំនួនលំនៅឋានដែលមានតម្លៃសមរម្យមានន័យថាបង្កើតសហគមន៍ដែលរីកចម្រើន និងរស់រវើកសម្រាប់អ្នករស់នៅទាំងអស់។ទូរស័ព្ទទៅអ្នកតំណាងរបស់អ្នក ហើយប្រាប់ពួកគេឱ្យគាំទ្រ H.4138 ដែលជាច្បាប់ផ្ទះដែលមានតម្លៃសមរម្យ ដើម្បីធ្វើឱ្យប្រាកដថាអ្នកគ្រប់គ្នានៅក្នុងរដ្ឋ Massachusetts មានសិទ្ធិទទួលបានលំនៅដ្ឋានស្មើគ្នាដែលពួកគេអាចមានលទ្ធភាពទិញបាន។ នៅពេលដែលមនុស្សគ្រប់គ្នាមានកន្លែងរស់នៅ យើងទាំងអស់គ្នាទទួលបានអត្ថប្រយោជន៍។ ដើម្បីស្វែងយល់បន្ថែមអំពីលំនៅឋានសមរម្យ សូមទាក់ទងកម្មវិធីលំនៅឋានសមរម្យរបស់ក្រុមការងារសហគមន៍ តាមរយៈលេខ (978) 654-5637 ឬចូលទៅកាន់ទំព័រកម្មវិធីលំនៅឋានសមរម្យនៅcommteam.org។

លំនៅដ្ឋានដែលមានតម្លៃសមរម្យ និងអាចចូលប្រើប្រាស់បានជួយមនុស្សចាស់នៅក្នុងសហគមន៍ និងជួយគ្រួសារដែលរីកចម្រើន និងច្រើនជំនាន់ស្វែងរកលំនៅដ្ឋានដែលបំពេញតម្រូវការរបស់ពួកគេ។ យើងទាំងអស់គ្នាត្រូវគាំទ្រគោលនយោបាយក្នុងស្រុកដែលគាំទ្រដល់ការអភិវឌ្ឍន៍លំនៅដ្ឋានដែលមានតម្លៃសមរម្យ។ ដើម្បីស្វែងយល់បន្ថែមអំពីលំនៅឋានសមរម្យ សិទ្ធិលំនៅឋាន និងជម្រើសលំនៅដ្ឋានសូមទាក់ទងកម្មវិធីលំនៅឋានសមរម្យនៅក្រុមការងារសហគមន៍ (978)654-5637 ឬចូលទៅកាន់ទំព័រកម្មវិធីលំនៅឋានសមរម្យនៅcommteam.org។



តមកពីទំព័រទី ០៥

## លោក កឹម សុខា បន្តបដិសេធ...



មេធាវីការពារក្តីលោក កឹម សុខា

ជាតិលោក កឹម សុខា ឲ្យជាប់ពន្ធនាគាររយៈពេល ២៧ឆ្នាំ ដោយឃុំខ្លួនក្នុងផ្ទះ ពីបទគប់គិតជាមួយរដ្ឋបរទេស ដើម្បីផ្តួលរំលំរដ្ឋាភិបាលរបស់លោក ហ៊ុន សែន បន្ទាប់ពីលោក កឹម សុខា ត្រូវបានសមត្ថកិច្ចសម្រុកចូលទៅចាប់ខ្លួនដល់ផ្ទះកាលពីយប់ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៧ ហើយគណបក្សសង្គ្រោះជាតិ ត្រូវបានតុលាការកំពូលក្រុងភ្នំពេញ ប្រកាសរំលាយកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៧ ដដែលនោះ។

សំណុំរឿងរបស់លោក កឹម សុខា កំពុងដំណើរការនៅសាលាឧទ្ធរណ៍សព្វថ្ងៃនេះ។ តុលាការថ្នាក់កណ្តាលមួយនេះ បានសម្រេចបើកសវនាការលើសំណុំរឿងនេះត្រឹមតែ ៩លើកប៉ុណ្ណោះ ហើយនឹងត្រូវធ្វើឡើង ២ដងក្នុង ១ខែ នៅរៀងរាល់ព្រឹកថ្ងៃព្រហស្បតិ៍ ដូច្នេះ បើគិតមកទល់នឹងពេលនេះ តុលាការបានបើកសវនាការបានចំនួន ៦លើកហើយ គឺលើកទី១ នៅថ្ងៃទី៣០ ខែមករា លើកទី២ នៅថ្ងៃទី៨ ខែកុម្ភៈ និងលើកទី៣ នៅថ្ងៃទី២២ ខែកុម្ភៈ លើកទី៤ គឺនៅថ្ងៃទី៧ ខែមីនា និងលើកទី៥ គឺនៅថ្ងៃទី២១ ខែមីនា និងលើកទី៦ នៅថ្ងៃទី ៤ ខែមេសា ឆ្នាំ២០២៤ នេះ។

សវនាការលើសំណុំរឿងរបស់លោក កឹម សុខា ក្នុងសាលាឧទ្ធរណ៍នៅសល់តែ ៣លើកទៀតប៉ុណ្ណោះនឹងត្រូវតុលាការសម្រេចប្រកាសសាលក្រម ខណៈលទ្ធផលនៃសវនាការនេះ គេរំពឹងថាសាលាឧទ្ធរណ៍នឹងចាត់ទុកសាលក្រមរបស់សាលាដំបូងជាបានការដដែល ក្នុងនោះ គេក៏រំពឹងដែរថា បើលោក កឹម សុខា ប្តឹងទៅតុលាការកំពូលបន្តទៀតនោះលទ្ធផលក៏មិនខុសគ្នាពីសាលាដំបូងដែរ ព្រោះគេដឹងថាតុលាការកម្ពុជាសព្វថ្ងៃនេះ គឺស្ថិតក្រោមបញ្ជារបស់លោក ហ៊ុន សែន ប៉ុណ្ណោះ។

សំណុំរឿងប្រធានគណបក្សសង្គ្រោះជាតិលោក កឹម សុខា ត្រូវបានគេចាត់ទុកថាជាសំណុំរឿងដែលយូរជាងគេក្នុងប្រវត្តិនៃការកាត់ក្តីនៅកម្ពុជា ហើយបញ្ហានេះត្រូវមជ្ឈដ្ឋាននានារិះគន់ថាជាសំណុំរឿងដែលស្ថិតក្នុងរបៀបវារៈនយោបាយ ជាជាងការស្វែងរកយុត្តិធម៌តាមប្រព័ន្ធតុលាការ ត្បិតតុលាការកម្ពុជាត្រូវគេមើលឃើញថាជាស្ថាប័នដែលលម្អៀង និងបម្រើផលប្រយោជន៍ឱ្យបក្សកាន់អំណាចរហូតមក៕

តមកពីទំព័រទី ២៧

## អភិបាល Healey បានប្រកាសពី...

Lowell បានមានប្រសាសន៍ "UMass Lowell មហាវិទ្យាល័យជំនាញលំដាប់កំពូលជាច្រើន ហើយយើងចាប់ដៃគូជាមួយអង្គការឧស្សាហកម្មផ្សេងទៀត"។ "សូមថ្លែងអំណរ គុណដល់រដ្ឋបាល Healey-Driscoll និងដៃគូ ដូចជា Draper UMass Lowell នឹងអាចពង្រីកការស្រាវជ្រាវជុំវិញលំហអាកាសការអនុវត្តរបស់មនុស្ស វាយនភណ្ឌកម្រិតខ្ពស់ មនុស្សយន្ត ឧបករណ៍ចាប់សញ្ញា និងវិស័យជាច្រើនទៀតដែលនឹងនាំមកនូវភាពសម្បូរបែបនៃការអប់រំ និងឱកាសការងារសម្រាប់ទីក្រុងឡូវែល"។

លោកបណ្ឌិត Jerry M. Wohletz នាយកប្រតិបត្តិ និងជាប្រធានក្រុមហ៊ុន Draper បានមានប្រសាសន៍ថា "ការពង្រីករបស់យើងទៅកាន់ទីក្រុងឡូវែល គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយនៅក្នុងបេសកកម្មរបស់យើងក្នុងការជំរុញការច្នៃប្រឌិតនៅក្នុងរដ្ឋម៉ាសាឈូសេត និងនៅទូទាំងសហរដ្ឋអាមេរិក"។ "យើងមានអរគុណចំពោះអភិបាល Healey ក្រុមរបស់លោកស្រី និងសាកលវិទ្យាល័យម៉ាសាឈូសេតឡូវែល សម្រាប់ភាពជាដៃគូរបស់ពួកគេ។ សាកលវិទ្យាល័យគឺជាក្បាលម៉ាស៊ីននៃការច្នៃប្រឌិត ជាមួយនឹងគំនិតដ៏មានឥទ្ធិពលដែលពិភពលោកត្រូវការ ប៉ុន្តែការធ្វើឱ្យគំនិតទាំងនោះក្លាយជាការពិតមិនមែនជាកិច្ចការតូចតាចនោះទេ។ Draper នៅទីនេះ ដើម្បីជួយផ្តល់ការណែនាំ ការសាកល្បងគំរូ ការអភិវឌ្ឍ និង ផ្តល់ឱកាសសម្រាប់កិច្ចសហការជាមួយអតិថិជនទទួលលទ្ធផលមានដំណោះស្រាយ និងដាក់ឱ្យប្រើប្រាស់"។

អ្នកគ្រប់គ្រងទីក្រុងឡូវែល លោក Thomas A. Golden, Jr. បានមានប្រសាសន៍ថា ទីក្រុងមានសេចក្តីរំភើបរីករាយស្វាគមន៍ Draper មកកាន់ទីក្រុងឡូវែល និងជឿជាក់ថា ការងារសហការជាមួយសាកលវិទ្យាល័យនៅលើ LINC នឹងនាំមកនូវក្រុមហ៊ុនជាច្រើនទៀតដែលមានទំនាក់ទំនងជាមួយសាកលវិទ្យាល័យ ហើយចង់ធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការដូចជា Draper។

លោក Golden បានមានប្រសាសន៍ថា "LINC នឹងរក្សា និងទាក់ទាញអ្នកជំនាញមកកាន់ទីក្រុងឡូវែលក៏ដូចជាបង្កើនការកម្សាន្ត និងវប្បធម៌អភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចសម្រាប់អ្នករស់នៅទីក្រុងឡូវែល" ដោយបន្ថែមថា ទីក្រុង និង UMass Lowell ក៏កំពុងរៀបចំផែនការកែលម្អហេដ្ឋារចនាសម្ព័ន្ធផងដែរ ខណៈដែលមនុស្សកាន់តែច្រើនកំពុងរស់នៅ និងធ្វើការនៅទីក្រុងឡូវែល។

ចូលទៅកាន់គេហទំព័រ https://www.lowell-inc.com/ ដើម្បីស្វែងយល់បន្ថែមអំពី LINC និងផែនការយុទ្ធសាស្ត្រដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅទីក្រុងឡូវែល៕

## Kem Sokha continues to deny that he did not conspire with foreign states to overthrow the government as alleged

From Page 05

nicipal Court which decided to sentence him to 27 years in prison for "treason." She said that Mr. Kem Sokha claimed to defend his innocence that he did not conspire with foreigners as alleged.

ADHOC Human Rights Defenders Yi Soksan, who attended the hearing, said that the hearing on Wednesday, April 3, debated three facts: first, Black Monday, second, Pink and third Fist. He said Kem Sokha still denied that he had conspired with foreigners.

On March 3, 2023, the Phnom Penh Municipal Court sentenced CNRP president Kem Sokha to 27 years in prison under house arrest for conspiring with a foreign state to overthrow Hun Sen's government. Kem Sokha was raided and arrested at home on the night of September 3, 2017, and the CNRP was dissolved by the Phnom Penh Supreme Court on November 16, 2017.

Kem Sokha's case is proceeding in the Court of Appeal today. The Court of Appeal (center court) has decided to hear the case only nine times and will hold it twice a month every Thursday morning, so far, the court has held six hearings. The first on January 30, the second on February 8 and the third on February 22, the fourth on March 7 and the fifth on March 21 and the sixth time on April 4, 2024.

With only three hearings left in Kem Sokha's case at the Court of Appeal, the verdict will be announced as the outcome of the trial is expected to be upheld by the Court of Appeal. That if Mr. Kem Sokha continues to appeal to the Supreme Court, the results will not be different from the court, because it is known that the Cambodian court today is under the order of Mr. Hun Sen.

The case of CNRP President Kem Sokha is considered to be the longest in the history of the trial in Cambodia, and this issue has been criticized by the publics as a case that is on the political agenda rather than seeking justice. The Cambodian judiciary has always been seen as an institution that is biased and serves the interests of the ruling party.






# កំណើតនគរអច្ឆរិយៈ

## ព្រះថោងចាកចេញនគរកំណើតឥន្ទបត្តបុរី តោងស្បៃនាងនាគចូលស្ថានភុជង្គ

**ដោយៈ រីស្គា គួច - Richard KUOCH**

ព្រោះតាមទំនាយថាថ្ងៃក្រោយទៅ ប្រជារាស្ត្ររស់នៅនគរព្រះអង្គ នឹងក្លាយជាអ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន។ ( ចំណេរកាលក្រោយមក ព្រះបាទធម្មោរាជា បិតាព្រះអង្គចន្ទទី១ យកព្រះពុទ្ធរូបនេះតម្កល់លើបល្ល័ង្កធ្វើពីឈើក្រអូប ទុកក្នុងប្រអប់ធ្វើពីមាសសុទ្ធ ហើយដាក់ក្នុងប្រាសាទធ្វើពីស្ពាន់ក្រហម ប្រសិទ្ធនាមថា » ប្រាសាទព្រះសាស្តា»(ប្រតិស្ថានទុកក្នុងចេតិយលើភ្នំសន្ទុកក្នុងខេត្តកំពង់ធំសព្វថ្ងៃ)(យោងតាមឯកសារលោក Adhémard LECLERE) ។

បីខែកន្លងមក សំពៅប្រាំប្រក់ដោយដងក្តោងដ៏មាំ ដឹកព្រះថោង ពលយោធា និងប្រជារាស្ត្រឆ្លងកាត់ជ្រោយម៉ាឡាកា(Ishme de Kra) ដែលនៅពេលនោះ ជាច្រកសមុទ្រចេញចូលនាវាធំៗទាក់ទងពាណិជកម្មរវាងប្រទេសជាច្រើន តាំងពីទ្វីបអឺរុប ជាមួយប្រទេសចិន ឥណ្ឌាជាការចាប់ផ្តើមហូរចូលវប្បធម៌ហិណ្ឌូ និងព្រះពុទ្ធសាសនាផងដែរ(Claude Jacque et Michel Freeman) ។ កងពលសំពៅព្រះថោង ឆ្លងផុតជ្រោយម៉ាឡាកាហើយ ក្រឡេកឃើញច្រាំងផ្ទៃដីនៅមិនឆ្ងាយប៉ុន្មានទៀតទេ។ទាំងអស់គ្នាសប្បាយរីករាយ ព្រោះនៅកណ្តាលសមុទ្រយូរខែហើយ។ តែសេចក្តីត្រេកអរមិនបានប៉ុន្មានផង ស្រាប់តែឃើញកងទ័ពទូក-ង (ជាទូកចម្បាំងប្រដេញមានល្បឿនលឿន សម័យនោះខ្មែរប្រើសម្រាប់ធ្វើសង្គ្រាមផង និងសម្រាប់ប្រដេញសំពៅដែលចូលដល់តំបន់កាន់កាប់ ហើយមិនព្រមបង់ពន្ធ) រាប់រយរាប់ពាន់ចែវសំដៅមក បើកក្បួនឡោមព័ទ្ធសំពៅជំជិត។ មេទ័ពស្រីមេបញ្ជាការ ជិះលើទូកធំប្រណីតរំលេចដោយក្បាច់ចម្លាក់ម្កុរ បរលឿនចេញពីហ្វូងទូកក្បួនទ័ព បញ្ជាឲ្យមនុស្សក្នុងសំពៅទម្លាក់អាវុធ ហើយចុះចេញពីសំពៅ។ កងទ័ពព្រះថោងមិនព្រមទម្លាក់អាវុធ ទ្រង់បញ្ជាឲ្យទម្លាក់ទូកតូចៗពីសំពៅមកក្នុងទឹក ប្រុងប្រៀបប្រយុទ្ធការពារខ្លួន។ ព្រះថោងនឹកដល់ផ្នូសិល្ប៍ជ័យ ដែលព្រះឥសីនិមិត្តប្រាប់ ទ្រង់ក៏ចាប់លើកឡើងផ្សងថា បើខ្ញុំ



ព្រះអង្គមានវាសនា បានគ្រប់គ្រងទឹកដីតំបន់នេះ សូមឲ្យព្រួញបាញ់ទៅមានប្រសិទ្ធភាព អាចបង្ក្រាបកងទ័ពសត្រូវបាន។ សរចេញផុតពីខ្សែធ្នូលាន់សូរដូចរន្ទះ ចូលទៅទម្លុះទូកធំរបស់មេទ័ពស្រី ដែលកំពុងស្លន់ស្លោដោយសម្លេងខ្ទរខ្ទា ធ្វើឲ្យទូកបែកខ្ទាត់ខ្ទាយ មេទ័ពស្រីនិងកងការពារ ព្រមទាំងស្រីបម្រើធ្លាក់ចូលទឹក។ កងទ័ពនគរភ្នំមិនទាន់ភ្ញាក់ខ្លួនពីភាពស្រឡាំងកាំងភ្លឹកស្មារតីផង កងទ័ពព្រះថោងនៅក្នុងទូកតូចៗ ចូលទៅស្រង់មនុស្សដែលធ្លាក់ទឹកទាំងអស់ ឡើងមកដាក់ក្នុងសំពៅ។ ព្រះថោងឲ្យយកសំពត់ មកគ្របដណ្តប់មនុស្សទាំងនោះ ឲ្យបាត់រងាផង ឲ្យជិតខ្លួនផង ព្រោះអ្នកទាំងនោះមិនទាន់ចេះស្លៀកពាក់ បិទបាំងកេរ្តិ៍ខ្មាស ដោយស្លៀកតែប៉ឹងបន្តិចបន្តួច។ បន្ទាប់ពីបានសម្រាកស្រួលបួលហើយ ព្រះថោងយាងព្រះនាងសោមាមេទ័ពស្រី មករៀបរាប់ថ្វាយពីការធ្វើដំណើរដ៏វែងឆ្ងាយរបស់ព្រះអង្គ រហូតចូលមកដល់ទឹកដីនេះដោយគ្មានគោលបំណងចង់មកឈ្លានពានដែនដីរបស់ព្រះនាងទេ។ ព្រះនាងសោមាមេទ័ពស្រី ចាប់ចិត្តស្នេហាលើព្រះថោង ហើយក៏ស្នើឲ្យព្រះថោងគង់នៅទីនេះចុះ។ ព្រះថោងសុំតំបន់មួយកន្លែង ដើម្បីបោះបន្ទាយ ទ្រង់រៀបចំទីតាំងរួចរាល់ហើយ បញ្ជាឲ្យកងទ័ពជញ្ជូនឥវ៉ាន់ចូលបន្ទាយ។

ថ្ងៃនេះមេឃស្រឡះល្អ ព្រះនាងសោមាយាងព្រះថោងទតទេសភាពតាមមាត់សមុទ្រលើឆ្នេរខ្សាច់។ ពេលថ្ងៃក្តៅខ្លាំងក៏នាំគ្នាចុះហែលទឹកលេងសប្បាយសើចក្អាកក្អាយ ព្រះថោងពោលពាក្យលែបខាយផ្តោះផ្តង រហូតយល់ចិត្តគ្នាទៅវិញទៅមក។ ពន្លកស្នេហ៍រវាងព្រះថោងនិងនាងសោមាចាប់មានឡើង ព្រោះជាគូនិស្ស័យពីអតីតជាតិ។ ពេលឡើងពីទឹកមក គូស្នេហ៍ថ្មោងថ្មី បណ្តើរគ្នាត្រសងផុតឆ្នេរខ្សាច់កាត់ផ្ទាំងសិលាច្រាំងសមុទ្រ ពោលពាក្យពេចន៍ស្នេហាផ្អែមល្ហែម មិនចេះអស់មិនចេះហើយ។ កងការពារមួយកងតូចនិងព្រះនាងរជ្ជនី ដើរតាមពីក្រោយ។ គួរឲ្យអនិច្ចាព្រះនាងរជ្ជនីឃើញគេស្និទ្ធស្នាលគ្នា ពោរពេញទៅដោយទឹកដមស្នេហ៍ មានអារម្មណ៍រវើរវាយអស់សង្ឃឹម នឹកតូចចិត្តព្រោះខំចាកចេញពីនគរតាមគេមក មិនគិតពីគ្រោះថ្នាក់ឬលំបាកអ្វីឡើយ ដោយសង្ឃឹមថានឹងបានទទួលសេចក្តីស្នេហាពីគេ។គិតដល់ត្រង់នេះ សេចក្តីសោកសៅគ្របដណ្តប់ដួងចិត្តភ្លឹកភ្លាំងវិញ្ញាណ ភ្លាត់ជើងដួលផ្ងារក្រោយ បោកក្បាលលើដុំសិលា ចេញឈាមយ៉ាងច្រើន សុគតរលត់វិញ្ញាណយ៉ាងអាណោចអាធ័ម។ ព្រះថោងដើរយូរបន្តិច បាត់មិនឃើញប្អូន ដើរត្រឡប់ក្រោយវិញ ឃើញរាងកាយប្អូនដេកស្តូកស្តឹងលើផ្ទាំងថ្មក្នុងថ្លុកឈាមក៏ស្ទុះទៅត្រកងបីប្រាណប្អូន យំសោកជាខ្លាំង សោកស្តាយទឹកចិត្តប្អូនដែលខំស្រឡាញ់ ព្រះអង្គយ៉ាងផ្សូរផ្សាច់។ ព្រះថោងបីសាកសពព្រះអនុជ រហូតដល់បន្ទាយ (ដាក់ចម្រៀង) ចាត់ចែងធ្វើបុណ្យ តាមប្រពៃណីព្រហ្មញ្ញសាសនា។

ក្រោយផុតកំណត់កាន់ទុក្ខសពព្រះនាងរជ្ជនី ព្រះនាងនាគ(សោមា) យាងព្រះថោងទៅជួបព្រះមាតា បិតានៅឋានភុជង្គនាគ។ ដើម្បីអាចមុជជ្រែកមហាសាគរបាន ព្រះនាងនាគ(សោមា) ឲ្យព្រះថោងតោងជាយស្បៃ ហែលតាមក្រោយទៅ ដែលជាប់ជាដំណែលទម្លាប់ប្រពៃណីរបស់ខ្មែររហូតមក នៅពេលរៀបអាពាហ៍ពិពាហ៍មង្គលកូនប្រុសស្រី មេបាតែងតម្រូវឲ្យកូនប្រុសតោងស្បៃកូនស្រីចូលបន្ទប់ផ្សំដំណេក។

### ព្រះបាទអទិច្ចវង្សាសោយរាជ្យនៅនគរគោកធ្លក មានព្រះមហេសីព្រះនាមសោមាភគវតី

ស្តេចនាគរៀបចំពិធីការ ថ្វាយបុត្រីរួចរាល់ហើយ ទ្រង់នាំសេនាហែហមបុត្រទាំងទ្វេឡើងមកស្ថានកណ្តាល បង្គាប់ឲ្យសេនាខាងស្ថាបត្យកម្ម បឺតទឹកសមុទ្រឲ្យស្រកចុះ កើតបាន ជាមហានគរ មានផែនដីធំទូលាយ ហើយស្ថាបនារាជធានី មានប្រាសាទល្អប្រណីតថ្វាយបុត្រី។ នៅចំកណ្តាលកោះដ៏ធំនោះ មានដុះដើមធ្លកធំមួយដើម ទើបប្រតិស្ឋនាមថា«នគរគោកធ្លកបវរស្វស្តី » លើកព្រះថោងឡើងសោយរាជ្យជាស្តេចព្រះនាមថា«ព្រះបាទអទិច្ចវង្សា » មាន ព្រះនាងនាគ ដែលត្រូវបានថ្វាយព្រះនាមថា «ព្រះនាងសោមាភគវតី »ជាអគ្គមហេសី។ ស្តេចភុជង្គនាគបានថ្វាយ »ដាវពិជ័យនាគរាជ »តម្កល់ទុកក្នុងព្រះនគរ ជាវត្ថុស័ក្តសិទ្ធិ៍ទុកជាទីសក្ការៈប្រចាំនគរតំណវង្ស។ ព្រះចៅអទិច្ចវង្សា ជាស្តេចទ្រង់ទសពិធរាជធម៌ មានប្រាជ្ញាឈ្លាសវៃ គ្រប់គ្រងរដ្ឋដោយគតិបណ្ឌិត បង្កើតច្បាប់យកជាគោលការណ៍ រៀបចំរចនាសម្ព័ន្ធរដ្ឋបាលយ៉ាងមានប្រសិទ្ធភាព ដោយបង្កើតជាភូមិ ឃុំ ស្រុក ខេត្តខណ្ឌ មានភ្នាក់ងារត្រួតត្រាគ្រប់គ្រងជាអ្នកមានសមត្ថភាព ដឹកនាំប្រជារាស្ត្រ ទៅតាមគោលការណ៍តាមព្រះរាជាបញ្ញត្តិ។ ព្រះបាទអទិច្ចវង្សា បង្រៀនប្រជាជនឲ្យចេះត្បាញវែកប្បាសធ្វើជាសម្លៀកបំពាក់ ព្រោះមកដល់ពេលនេះពួកគេស្រាតនលស្លៀកប៉ឹងបិទបាំងកេរ្តិ៍ខ្មាសតែបន្តិចបន្តួច និងមានសាក់ពេញខ្លួន។ ប្រជាជននៅកោះគោកធ្លកពេលនោះ រស់នៅជាជនពនេចរ ផ្លាស់ប្តូរទីកន្លែងរស់នៅទៅតាមរដូវកាល ពីតំបន់មួយទៅតំបន់មួយ។ ព្រះអង្គបង្រៀនឲ្យចេះធ្វើផ្ទះសង់លំនៅស្ថានបង្កើតជាភូមិ ចេះដាំដំណាំចិញ្ចឹមសត្វ ជាពិសេសចេះ

**តទៅលេខក្រោយ**

សារព័ត៌មាន ខ្មែរផុស ស.រ.អា

Free Copies

Email:Khmerpostusa@gmail.com
www.khmerpostusa.com

# KhmerPost USA

Vol. 15. Issue 361, Apr 10, 2024 | Direct: 978-656-8141 Lowell - Lynn - Revere - MA * Providence - Cranston - RI

# ការអំពាវនាវកើនឡើង ដើម្បីយកដីត្រឡប់មកវិញ ដែលត្រូវបានរំលោភ យកតាមគោលនយោបាយ ស្ដីពីសម្បទានដីសេដ្ឋកិច្ចរបស់កម្ពុជា

- ការគ្រប់គ្រងដីធ្លីនៃប្រទេសកម្ពុជាមិនត្រឹមត្រូវដោយពួកឥស្សរជនក្រោមគោលនយោបាយសម្បទានដីសេដ្ឋកិច្ច បានជម្លៀសប្រជាជននៅតាមជនបទរាប់ពាន់គ្រួសារ ស្មើនឹង ៤០% នៃការកាប់បំផ្លាញព្រៃឈើសរុប។
- រដ្ឋាភិបាលហាក់បីដូចជាទទួលស្គាល់នូវភាពគ្មានប្រសិទ្ធភាពនៃគោលនយោបាយសម្បទានដីសេដ្ឋកិច្ច (ELCs) ជាកត្តាជំរុញសេដ្ឋកិច្ច ការអំពាវនាវកំពុងកើនឡើងដើម្បីប្រគល់ដីដែលត្រូវបានដកហូតទៅឲ្យសហគមន៍ ឬយកមកវិញសម្រាប់គោលបំណងផ្សេងទៀត។

តទៅទំព័រទី១២

## Calls grow to repurpose land squandered in Cambodia's concession policy

*by Gerald Flynn on 8 November 2023*

- *The mismanagement of large swaths of Cambodia's land by the country's elites under the policy of economic land concessions has displaced thousands*

Please see /12



## «ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ»ទើបនឹងផុសចេញមកនៅសហរដ្ឋអាមេរិក

សូមអាននៅទំព័រទី០២



## លោក កើត សារ៉ាយ និស្សិតបញ្ញវ័ន្តខ្មែរត្រូវបានចាប់ខ្លួន




លោកកើតសារ៉ាយ ជាប្រធានសមាគមន៍សម្ព័ន្ធនិស្សិតបញ្ញាវន្តខ្មែរត្រូវបានចាប់ខ្លួនជាលើកទី២ បន្ទាប់ពី

សូមអាននៅទំព័រទី១៦

## ការចាប់ខ្លួន ការចាប់ដាក់គុក និងការស្លាប់មនុស្សជាច្រើននាក់ បន្ទាប់ពីការបណ្ដេញចេញដោយបង្ខំរបស់រដ្ឋាភិបាលក្នុងខេត្តព្រះវិហារ ប្រទេសកម្ពុជា

កាលពីថ្ងៃទី ១៥ ខែមីនា បន្ទាប់ពីកងកម្លាំង

សូមអាននៅទំព័រទី០៩






មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL

Excellent Service Since 1987

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987

គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា

សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្លូវច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបានបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។
បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense




Thank you for your continued confidence
In our office to handle your legal and tax matters.
We look forward to serving you well into the future.

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com